ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២២-៨-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៨១៣/៨៩៥ ស្តីពី ការតែងតាំងលោក **គាត សុជាតិ** ជា ឧកញ៉ា ៨២៩៨

២២-៨-២០១៣ -ព្រះរាជក្រឹត្យ នស/រកត/០៨១៣/៨៩៦ ស្តីពី ការតែងតាំងលោក **ម៉ុន ចាន់នី** ជា ឧកញ៉ា ៨២៩៩


## II~ក្រុមប្រឹក្សាធម្មនុញ្ញ


០៤-៧-២០១៣ -សេចក្តីសម្រេចលេខ ២២/២០១៣ កបធ.សសរ ស្តីពី ការចាត់តាំងអ្នកនាំពាក្យក្រុមប្រឹក្សាធម្មនុញ្ញ ៨៣០០

០៤-៧-២០១៣ -សេចក្តីសម្រេចលេខ ២៣/២០១៣ កបធ.សសរ ស្តីពី ការបែងចែកក្រុម នៃក្រុមប្រឹក្សាធម្មនុញ្ញ ៨៣០១

១៥-៨-២០១៣ -សេចក្តីសម្រេចលេខ ១២៨/០០៣/២០១៣ កបធ.ច ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០១៣ លើសំណុំរឿង លេខ ២១៣/០១៧/២០១៣ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ ២០១៣ ៨៣០៤

២៩-៨-២០១៣ -សេចក្តីសម្រេចលេខ ១២៩/០០៤/២០១៣ កបធ.ច ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ ២០១៣ លើសំណុំរឿង លេខ ២៣១/០៣៥/២០១៣ ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៣ ៨៣១១

៣១-៨-២០១៣-សេចក្តីសម្រេចលេខ ១៣០/០០៥/២០១៣ កបធ.ច ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០១៣ លើសំណុំរឿង លេខ ២២៦/០៣០/២០១៣ ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៣ ៨៣១៧

០១-៩-២០១៣ -សេចក្តីសម្រេចលេខ ១៣១/០០៦/២០១៣ កបធ.ច ចុះថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០១៣ លើសំណុំរឿង លេខ ២៣៣/០៣៧/២០១៣ ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០១៣ ៨៣៣៦


## III~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


២៦-៨-២០១៣ -អនុក្រឹត្យលេខ ៤៧៥ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៨៣៤២

២៦-៨-២០១៣ -អនុក្រឹត្យលេខ ៤៧៦ អនក្រ.បក ស្តីពី បរធនបាលកិច្ចហិរញ្ញវត្ថុ ៨៣៤៤

៣០-៨-២០១៣-អនុក្រឹត្យលេខ ៩៧៧ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៨៣៥៥
០២-៧-២០១៣-អនុក្រឹត្យលេខ ៨៥២ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៨៣៥៧
០២-៧-២០១៣-អនុក្រឹត្យលេខ ៨៥៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៣៥៨
០២-៧-២០១៣-អនុក្រឹត្យលេខ ៨៥៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៣៥៩
០២-៧-២០១៣-អនុក្រឹត្យលេខ ៨៥៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៣៦១
០២-៧-២០១៣-អនុក្រឹត្យលេខ ៨៥៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៨៣៦៤
០២-៧-២០១៣-អនុក្រឹត្យលេខ ៨៥៧ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៨៣៦៦
០២-៧-២០១៣-អនុក្រឹត្យលេខ ៨៥៨ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៨៣៦៧
០២-៧-២០១៣-អនុក្រឹត្យលេខ ៨៥៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៨៣៦៩

## ២-សេចក្តីសម្រេច

០២-៩-២០១៣-សេចក្តីសម្រេចលេខ ២៧ សសរ ស្តីពី ការផ្ទេរសិទ្ធិការងាររបស់រាជរដ្ឋាភិបាល ៨៣៧៤

# IV-ការងារបណ្តាក្រសួង

## ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៣-៨-២០១៣-ប្រកាសលេខ ៨០២ សហវ.ប្រក ស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យ និងគណៈកម្មការវាយតម្លៃឯកសារដេញថ្លៃផ្គត់ផ្គង់ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ ៨៣៧៥
២៧-៨-២០១៣-ប្រកាសលេខ ៨០៨ សហវ.ប្រក ស្តីពី ការកែសម្រួលសមាសភាពក្រុមការងារចម្រុះនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អង្គភាពប្រឆាំងអំពើពុករលួយ និង ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សម្រាប់ពិនិត្យប្រាក់សម្រួលការងារ (កម្រៃសេវា) ៨៣៨០

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

១៣-៨-២០១៣-ប្រកាសលេខ ៦២៥ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ជេឌី & តូយូស៊ីម៉ា បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់ ៨៣៨៤
១៣-៨-២០១៣-ប្រកាសលេខ ៦២៦ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ចាកា ស៊ូ មេនូហ្វេកធើរី ខូ អិលធីឌី បង្កើតរោងចក្រ ផលិតស្បែកជើង ៨៣៨៨

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៣/៤៩៥

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ត្រាស់បង្គាប់

តែងតាំង :

លោក គាត សុជាតិ

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

ពរស. ១៣០៤. ៩០៩

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

លេខ: ៨៩៦ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១៣

**អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**

**ប៉យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៨១៣/៤៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ក្រាស់បង្គាប់

តែងតាំង :

លោក ប៊ុន ចាន់នី

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៣

ឡ្វងព្រះបរមនាម និងតាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**

ចារស. ១៣០៤.៩១០

លេខ: ៨៩០ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១៣

**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សយ សុខា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

លេខ:២២ /២០១៣ កបធ.សសរ

# សេចក្តីសម្រេច
## ស្តីពីការចាត់តាំងអ្នកនាំពាក្យក្រុមប្រឹក្សាធម្មនុញ្ញ

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
-យោងការសម្រេចរបស់កិច្ចប្រជុំពេញអង្គក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣
-តាមការចាំបាច់ចំពោះមុខរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

## សម្រេច

**ប្រការ ១.-** ចាត់តាំងឯកឧត្តម **ប្រាជ្ញ ញាណវិចិត្រ** និង ឯកឧត្តម **អ៊ុត ឈន** សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ជាអ្នកនាំពាក្យរបស់ក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ ឆ្នាំ លើកទី៦ ( ២០១៣-២០១៦ ) ។

**ប្រការ ២.-** ឯកឧត្តម **ប្រាជ្ញ ញាណវិចិត្រ** និង ឯកឧត្តម **អ៊ុត ឈន** និង អគ្គលេខាធិការដ្ឋាន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យបានលទ្ធផលល្អប្រសើរ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣
ជ.ក្រុមប្រឹក្សាធម្មនុញ្ញ
ប្រធាន

ឯក សំអុល

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- តុលាការកំពូល
- រាជកិច្ច
- សាមីខ្លួន
- ឯកសារ-កាលប្បវត្តិ

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខៈ៦៣ /២០១៣ កបធ.សសរ

# សេចក្តីសម្រេច

# ស្តីពីការបែងចែកក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ

## ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញបទបញ្ជាផ្ទៃក្នុងស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ

-យោងការសម្រេចរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងអង្គពិធីផ្ទេរភារកិច្ចសមាជិក សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០១៣

-យោងការសម្រេចរបស់កិច្ចប្រជុំពេញអង្គក្រុមប្រឹក្សាធម្មនុញ្ញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣

-តាមការចាំបាច់ចំពោះមុខរបស់ក្រុមប្រឹក្សាធម្មនុញ្ញ

## សម្រេច

**ប្រការ ១**.- ត្រូវបានបែងចែកក្រុមនៃក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់អាណត្តិ ៣ឆ្នាំ លើកទី៦ ( ២០១៣-២០១៦ ) ដូចខាងក្រោម :

**ក្រុមទី១**

១-ឯកឧត្តម **ឯក សំអុល**

២-សម្តេច **នរោត្តម សិរីវុឌ្ឍ**

៣-ឯកឧត្តម **អ៊ឹត ឈន**

**ក្រុមទី២**

១-ឯកឧត្តម **ព្រហ្ម ញាណទិចិត្រ**

២-អ្នកអង្គម្ចាស់ **ស៊ីសុវត្ថិ ផាន់ដារ៉ាវង្ស**

៣-ឯកឧត្តម **ម៉ឹន ស៊ាន**

**ក្រុមទី៣**

១-លោកជំទាវ **ចែម ទេយ្យរិទ្ធ**

២-សម្តេចព្រះមហិស្សរា **នរោត្តម ចក្រពង្ស**

៣-ឯកឧត្តម **ពិត តាំងសាន**

**ប្រការ ២.-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣.-** សេចក្តីសម្រេចនេះមានអានុភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៣

ឧត្តមក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

**ឯក សិរុណ**

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- តុលាការកំពូល
- រាជកិច្ច
- សាមីខ្លួន
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**
**អគ្គលេខាធិការដ្ឋាន**

លេខ: ៤៩/២០១៣ អ.កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣

**សូមគោរពជូន**
**ឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល**

**កម្មវត្ថុ** : សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១២៨/០០៣/២០១៣ កបធ.ច ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣

**យោង** : មាត្រា ៣៤ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

តាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល មេត្តាជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ០៩ ព្រឹក ក្រុមប្រឹក្សាធម្មនុញ្ញ បានពិនិត្យបណ្តឹងចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៣ របស់លោក **គុល ប្រាសាទ** ដែលប្តឹងជំទាស់សេចក្តីសម្រេច លេខ ០១១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង បានចេញជាសេចក្តីសម្រេច ដូចមានជូនភ្ជាប់មកជាមួយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាលមេត្តាជ្រាប និង ចាត់ការបន្តតាមការគួរ ។

សូមឯកឧត្តមអគ្គលេខាធិការ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**អគ្គលេខាធិការ**

**ចាន់ រ៉ាស៊ី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២១៣/០១៧/២០១៣

ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១២៨/០០៣/២០១៣ កបធ.ច

ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣

**ក្រុមប្រឹក្សាធម្មនុញ្ញ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញសេចក្តីសម្រេចលេខ ០១១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹង ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៣ របស់លោក **តុល ប្រាសាទ** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងជំទាស់នឹងសេចក្តីសម្រេចលេខ ០១១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៣ របស់លោក **ប៉ូ ចាន់ថេង** ផ្ទេរសិទ្ធិជូនលោក **តុល ប្រាសាទ** ធ្វើជាតំណាងក្នុងការដាក់ពាក្យបណ្តឹង និង សវនាការលើបណ្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចលេខ ០១១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុសួរយកចម្លើយរបស់លោក **តុល ប្រាសាទ** កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងរបស់លោក **តុល ប្រាសាទ** ខាងលើនេះ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១០ ព្រឹក គឺស្ថិតក្នុងរយៈពេលដែលច្បាប់អនុញ្ញាតក្នុងមាត្រា ៧៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ប្រការ ៨ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុង ស្តីពីនីតិវិធីដែលត្រូវអនុវត្តនៅមុខក្រុមប្រឹក្សាធម្មនុញ្ញ និង ប្រការ ១១.៩ ចំណុច ១១.៩.៣៦ នៃបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញ អាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន
- យល់ឃើញថា ការប៉ះទង្គិចគ្នារវាងក្បួនដង្ហែគណបក្សសង្គ្រោះជាតិ និង គណបក្សប្រជាជនកម្ពុជា ដែលសុទ្ធតែបានជូនដំណឹងដល់គណៈកម្មការរៀបចំការបោះឆ្នោតឃុំ កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ នៅឃុំកំពង់អុស គឺបណ្តាលមកពី ៖
  - គណៈកម្មការរៀបចំការបោះឆ្នោតឃុំកំពង់អុស គ្រាន់តែស្រង់ចម្លងពាក្យស្នើសុំរបស់គណបក្សទាំងពីរចូលក្នុងតារាង តែពុំបានធ្វើការសម្របសម្រួលកំណត់ទីភូមិសាស្ត្រក្នុងឃុំ ដើម្បីកុំឱ្យក្បួន

ដង្ហែគណបក្សដែលសុំឃោសនាចល័តក្នុងឃុំក្នុងថ្ងៃតែមួយដូចគ្នា ប៉ះទង្គិចគ្នា ដោយបណ្តោយឱ្យគណបក្សនីមួយៗឃោសនាតាមចិត្តរៀងៗខ្លួន ដូចនេះ ជាកំហុសឆ្គងរបស់គណៈកម្មការរៀបចំការបោះឆ្នោតឃុំកំពង់អុស ដែលពុំបានបែងចែកកាលវិភាគឱ្យបានច្បាស់លាស់ដើម្បីបញ្ចៀសកុំឱ្យមានការប៉ះទង្គិចគ្នា ពុំមែនជាកំហុសទាំងស្រុងរបស់សកម្មជនគណបក្សទេ ព្រោះសកម្មភាពរំខាននេះប្រព្រឹត្តទៅវិញទៅមកស្មើរពេញមួយថ្ងៃ ទោះបីជាមានការសម្របសម្រួលពីគណៈកម្មការរៀបចំការបោះឆ្នោតឃុំ និង គណៈកម្មការរៀបចំការបោះឆ្នោតខេត្តក៏ដោយ

- ទីតាំងភូមិសាស្ត្រផ្លូវតូចចង្អៀត ហើយមានប្រជាពលរដ្ឋធ្វើចរាចរណ៍ចុះឡើងជាច្រើនផង

- យល់ឃើញថា តាមការសាកសួររបស់ក្រុមគ្រូតពិនិត្យស្រាវជ្រាវរបស់គណៈកម្មការរៀបចំការបោះឆ្នោតឃុំកំពង់អុស កាលពីថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៣ ដល់ប្រជាពលរដ្ឋនៅភូមិព្រៃកតាម៉ែ ភូមិកំពង់អុស និង ភូមិដងគោម សុទ្ធតែឆ្លើយថា ពុំបានឃើញលោក **លឹម គានហោ** នៅក្នុងក្បួនដង្ហែ កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ ទេ
- យល់ឃើញថា តាមការអះអាងរបស់ លោក **អ៊ុង សារ៉េម** ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតឃុំកំពង់អុស ឆ្លើយនៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្ត ពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ ថា ពុំឃើញសកម្មភាពណាមួយដែលថា ឈ្មោះ **នង ណារ៉ុង** បានមករារាំង រំខានការឃោសនារបស់គណបក្សសង្គ្រោះជាតិទេ
- យល់ឃើញថា គួរមានវិធានការទៅលើជនដែលមិនគោរពតាមបទបញ្ជា និង នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ និង មិនទទួលយកការសម្របសម្រួលរបស់គណៈកម្មការរៀបចំការបោះឆ្នោតឃុំកំពង់អុស និង របស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកណ្តាល ។

## សម្រេច

**មាត្រា ១.-** ទទួលពាក្យបណ្តឹងចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៣ របស់លោក **តុល ប្រាសាទ** តំណាងគណបក្សសង្គ្រោះជាតិ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្តីសម្រេចលេខ ០១១/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តែបដិសេធចោលការលើកលែងមិនចាត់វិធានការលើឈ្មោះ **ទឹម សារុំធ នុត យ៉ាន់ណារ៉ូ បូរ សម្បត្តិ** និង **វង្ស សាឡន** ។

**មាត្រា ៣.-** ប្រគល់ភារកិច្ចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតធ្វើការព្រមានលោក **ទឹម សារ៉ុផ** លោក **នុត យ៉ាន់ណារ៉ូ** លោក **បូរ សម្បត្តិ** និងលោកស្រី **វង្ស សាឡន** ដែលមិនគោរពតាមបទបញ្ជា និង នីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ និង មិនទទួលយកការសម្របសម្រួលរបស់គណៈកម្មការរៀបចំការបោះឆ្នោតឃុំកំពង់អុសនិងរបស់គណៈកម្មការរៀបចំការបោះឆ្នោតខេត្តកណ្តាល ។

**មាត្រា ៤.-** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។ ៕/៚

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៣

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល
លេខ ៥.13/0.17/2013
ថ្ងៃ 11.សី.ហា.2013....
ម៉ោង ម.10:00....

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យបណ្តឹង**

ខ្ញុំបាទឈ្មោះ **គុល ប្រាសាទ** អាយុ ៤១ឆ្នាំ ជនជាតិ ខ្មែរ មានទីលំនៅផ្ទះលេខ ២៦៤ ផ្លូវជាតិលេខ២ ភូមិដើមមៀន សង្កាត់ដើមមៀន ក្រុងតាខ្មៅ ខេត្តកណ្តាល ជាតំណាងគណបក្ស សង្គ្រោះជាតិ ។

**សូមគោរពជូន**
**ឯកឧត្តម ប្រធាន ក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា**

*សូមជ្រាបជាទ!*

**កម្មវត្ថុ** ៖ ប្តឹងជំទាស់សេចក្តីសម្រេចលេខ ០១១ / ១៣ គ.ជ.ប.ស.សរ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**យោង** ៖ - ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បទបញ្ជា និងនីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥
- សេចក្តីសម្រេចលេខ០១១/១៣ គ.ជ.ប.ស.សរ ចុះថ្ងៃទី០៧ ខែសីហាឆ្នាំ២០១៣របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។
- លិខិតផ្ទេរសិទ្ធិរបស់លោក ប៉ូ ចាន់ថេង ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៣ ជូន ខ្ញុំបាទ គុល ប្រាសាទ

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ៖ កាលពីវេលាម៉ោង៧:៣០ ដល់ ១១:៣០ និងចាប់ពីម៉ោង១៤:០០ ដល់ ១៧:០០ ល្ងាច ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ គណបក្សសង្គ្រោះជាតិ បានធ្វើការដង្ហែក្បួនឃោសនា និងចែកខិត្តប័ណ្ណគោលនយោបាយរបស់ខ្លួនជូនដល់ពលរដ្ឋនៅទូទាំងឃុំកំពង់អុស ស្រុកពញាឮ ខេត្តកណ្តាល ហើយនៅថ្ងៃនោះមានការអុកឡុករារាំងរំខានពីគណបក្សប្រជាជនកម្ពុជា ដែលមានឈ្មោះដូចខាងក្រោម ៖

១ - ឈ្មោះ លឹម គានហោ ភេទ ប្រុស មុខងារជារដ្ឋមន្ត្រីក្រសួងធនធានទឹក បានបញ្ជាដោយប្រយោល ។

២ - ឈ្មោះ ទឹម សារុធ ភេទ ប្រុស អតីតជាអធិការនគរបាលស្រុកពញាឮ ធ្វើសកម្មភាពចូលអុកឡុក រារាំង រំខានដោយផ្ទាល់ ។

៣ - ឈ្មោះ នុត យ៉ាន់ណារ៉ូ ភេទ ប្រុស ជាជនដៃដល់ធ្វើសកម្មភាពផ្ទាល់ពេញមួយថ្ងៃចូលអុកឡុក រារាំង រំខាន និងបានប្រើហឹង្សាដោយចេតនាមកលើសកម្មជនគណបក្សសង្គ្រោះជាតិជាក់ស្តែង ។

៤ - ឈ្មោះ បូរ សម្បត្តិ ភេទ ប្រុស ជាជនដៃដល់ធ្វើសកម្មភាពផ្ទាល់ពេញមួយថ្ងៃចូលអុកឡុក រារាំង រំខាន និងបានប្រើហឹង្សាដោយចេតនាមកលើសកម្មជនគណបក្សសង្គ្រោះជាតិជាក់ស្តែង។

៥ - ឈ្មោះ វង្ស សាឡុន ភេទស្រី ធ្វើសកម្មភាពអុកឡុក រារាំងរំខានដោយផ្ទាល់ ។

៦ - ឈ្មោះ នង ណារ៉ុង ភេទ ប្រុស មុខងារជាមេឃុំកំពង់អុស បានបញ្ជា និងធ្វើសកម្មភាពអុកឡុក រារាំង រំខាន ហើយបានបញ្ចេញសកម្មភាពអកប្បកិរិយាក្មេងក្លាងនៅមុខមហាជន ព្រមទាំងចូលមកក្នុងក្បួន និងឈរពាំងមុខរថយន្តរបស់ខ្ញុំបាទទៀតផង ។ ហើយសកម្មភាពអុកឡុក រារាំង រំខាននៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ នេះ គឺមានការ

ឃើញ និងដឹងឮ ពីមន្ត្រី CEC និងPEC ផ្ទាល់ ។ ខ្ញុំបាទសូមបញ្ជាក់ជូន **ឯកឧត្តមប្រធាន** ជ្រាបទៀតថា៖ ដោយពិនិត្យឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) មិនបានដាក់ពិន័យ និងចាត់វិធានការណាមួយទៅលើជនទាំង៦នាក់ និងបក្សពួកឱ្យសមហេតុផល និងស្របតាមច្បាប់ និងបទបញ្ជា នីតិវិធី សម្រាប់ការបោះឆ្នោតឆ្នាំ២០១៣ឡើយ ហើយគ្រាន់តែចាត់វិធានការតិចតួចទៅលើមន្ត្រី CEC ទៅវិញ ដែលជាការបិទបាំងមុខមាត់ជនល្មើសឱ្យរួចផុតពីសំណាក់ច្បាប់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យពិចារណាឡើងវិញនូវសេចក្តីសម្រេចលេខ ០១១ / ១៣ គ.ជ.ប.ស.ស.រ ច.ៈថ្ងៃទី០៧ ខែ សីហា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឱ្យស្របតាមច្បាប់ និងបញ្ញានីតិវិធីសម្រាប់ការបោះឆ្នោតឆ្នាំ២០១៣ និតិកាលទី៥ ដែលបានកំណត់ ។

សូមបញ្ជាក់ជូនថាសំណុំរឿងនេះខ្ញុំបាទមានសាក្សីចំនួន ០៥នាក់ ៖

១ - លោក ម៉ៅ ឌីយ៉ាម៉ង់ ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល
២ - លោក ប៉ា សារិន ឃុំឈ្វាំង ស្រុកពញាឮ ខេត្តកណ្តាល
៣ - លោក អ៊ី សាតាំ ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល
៤ - លោក ហ៊ីន សឿន ឃុំកោះចិន ស្រុកពញាឮ ខេត្តកណ្តាល
៥ - លោក សំ អុល ឃុំកំពង់លួង ស្រុកពញាឮ ខេត្តកណ្តាល

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ អំពីខ្ញុំបាទ ៕

**រាជធានីភ្នំពេញ, ថ្ងៃទី.១១.....ខែសីហា ឆ្នាំ២០១៣**

**ស្នាមមេដៃស្តាំ**



**គុល ប្រាសាទ**

**ទំនាក់ទំនង៖**

- 011 749 136
- 092 895 634

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន

លេខ ១០៩/២០១៣ អ.កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣

**សូមគោរពជូន**

**ឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល**

**កម្មវត្ថុ** ៖ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១២៩/០០៤/២០១៣ កបធ.ច ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣។

**យោង** ៖ មាត្រា ៣៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។

តាមកម្មវត្ថុ និង យោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល មេត្តាជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ៨:៣០ នាទី ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **ជាម ច័ន្ទនី** តំណាងគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ាផ្ទៀងផ្ទាត់ឡើងវិញនៃទម្រង់ ១១០២ និងទម្រង់១១០៤ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តកំពង់ធំ ចំនួន ៩ ឃុំ និងបានចេញជាសេចក្តីសម្រេច ដូចមានជូនភ្ជាប់មកជាមួយ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាលមេត្តាជ្រាប និងចាត់ការបន្តតាមការគួរ។

សូមឯកឧត្តមអគ្គលេខាធិការ មេត្តាទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

អគ្គលេខាធិការ

**ឆាន់ រ៉ាស៊ី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៣១/០៣៥/២០១៣

ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១២៩/០០៤/២០១៣ កបធ.ច

ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញលិខិតលេខ ៨២៦/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **ជាម ច័ន្ទនី** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ាផ្ទៀងផ្ទាត់ឡើងវិញនៃទម្រង់ ១១០២ និង ទម្រង់ ១១០៤ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តកំពង់ធំ ចំនួន ៩ ឃុំ
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនឯកឧត្តម **ជាម ច័ន្ទនី** ធ្វើជាតំណាងគណបក្សសង្គ្រោះជាតិក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ន នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ មណ្ឌលខេត្តកំពង់ធំ
- បានឃើញលិខិតឧទ្ទេសនាមលេខ ៨៥៦ /១៣ គ.ជ.ប ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ជាម ច័ន្ទនី** កាលពីថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ឯម សូផាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៣ ចំនួនពីរទំព័រ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣របស់ឯកឧត្តម **ជាម ច័ន្ទនី** ខាងលើនេះដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ១៤:៤៥ នាទី គឺស្ថិតក្នុងរយៈពេលដែលច្បាប់អនុញ្ញាតក្នុងចំណុចទី២ មាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញនិងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ និងមាត្រា ១១៧ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន
- យល់ឃើញថា តាមខ្លឹមសារនៃពាក្យបណ្តឹងរបស់ឯកឧត្តម **ជាម ច័ន្ទនី** ចំណុចទី១ តវ៉ាឱ្យផ្ទៀងផ្ទាត់ឡើងវិញលើទម្រង់ ១១០២ និង ទម្រង់ ១១០៤ ចំនួន ៩ ឃុំ គឺឃុំឈូកខ្សាច់ ឃុំក្រវ៉ា ឃុំដឹរស្លាប់ ឃុំកំពង់ស្វាយ ឃុំសាន់គរ ឃុំផាន់ញើម ឃុំព្នៅ ឃុំសំព្រោជ និង សង្កាត់កំពង់រទេះ និងចំណុចទី២

ទាមទារឱ្យរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតខេត្តកំពង់ធំឡើងវិញ ដោយហេតុថា ប្រជាពលរដ្ឋបាត់ឈ្មោះច្រើន និងខ្លះទៀតត្រូវគេបោះជំនួស

- យល់ឃើញថា តាមការឆ្លើយបំភ្លឺនៅចំពោះមុខក្រុមទី២នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម **ជាម ច័ន្ទនី** សុំប្តឹងគ្រប់ការិយាល័យទាំងអស់នៅក្នុងឃុំទាំង ៩ ពីព្រោះប្រធានការិយាល័យប្រញាប់ប្រញាល់ពេក ។ ឯកឧត្តម **ជាម ច័ន្ទនី** បានបញ្ជាក់ថា លោកបានដាក់ភ្នាក់ងារសង្កេតការណ៍ គ្រប់ការិយាល័យនៅមណ្ឌលបោះឆ្នោតខេត្តកំពង់ធំ ។ តំណាងគណបក្សរបស់លោកបានចុះហត្ថលេខាទទួលស្គាល់ជាសាក្សីនៅលើគ្រប់ទម្រង់ ១១០២
- យល់ឃើញថា តាមលិខិតលេខ ៨២៦/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក៏ដូចជាការឆ្លើយបំភ្លឺរបស់ឯកឧត្តម **ឯម សូផាត** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ បានបញ្ជាក់ថា ឯកឧត្តម **ជាម ច័ន្ទនី** ពុំមានភស្តុតាងដាក់ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបញ្ជាក់ពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬ សមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីទីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះនិងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារឬភស្តុតាងដទៃទៀតស្របតាមមាត្រា ១១៤នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះទេ ។ ឯកឧត្តម **ជាម ច័ន្ទនី** ពុំមានភស្តុតាងបញ្ជាក់ពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយដែលតម្រូវឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ផ្ទៀងផ្ទាត់ឡើងវិញនូវទម្រង់ ១១០២ និង ១១០៤ នៅឃុំ សង្កាត់ចំនួន ៩ នៃមណ្ឌលខេត្តកំពង់ធំបានទេ
- យល់ឃើញថា ការទាមទារក្នុងចំណុចទី ២ នៅក្នុងពាក្យបណ្តឹងរបស់ឯកឧត្តម **ជាម ច័ន្ទនី** ជាកម្មវត្ថុថ្មីមិនមាននៅក្នុងពាក្យបណ្តឹងចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ ដាក់នៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ហើយក៏មិនទាក់ទងនឹងការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យល់ឃើញថា ពុំមានពាក្យបណ្តឹង ដាក់នៅគណៈកម្មការការិយាល័យរៀបចំការបោះឆ្នោតនិងរាប់សន្លឹកឆ្នោត ដាក់នៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ទាំង ៩ ឃុំ សង្កាត់ និងដាក់នៅគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកំពង់ធំ តាមកាលកំណត់ក្នុងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ទេ
- យល់ឃើញថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិចែងក្នុងមាត្រា ១១៥ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ និងស្របតាមបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥

- យល់ឃើញថា ការបោះឆ្នោតនៅមណ្ឌលខេត្តកំពង់ធំ ពុំមានអំពើហិង្សា និងពុំមានចលាចលវឹកវរទេ។ ប្រជាពលរដ្ឋបានបោះឆ្នោតដោយសម្ងាត់ និងដោយសេរី
- យល់ឃើញថា លិខិតលេខ ៨២៦/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## សម្រេច

**មាត្រា ១.-** ទទួលពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **ជាម ច័ន្ទនី** តំណាងគណបក្សសង្គ្រោះជាតិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់លិខិតលេខ ៨២៦/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។៚

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៣

ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល
លេខ. ២៣១/០៨៥/២០១៣
ថ្ងៃ.....១៧ សីហា ២០១៣
ម៉ោង.. ៤.៤៥ ល្ងាច

## ពាក្យបណ្តឹងតវ៉ា

ខ្ញុំបាទឈ្មោះ **ជាម ច័ន្ទនី** ឆ្នាំកំណើត ១៩៦១ ជាតំណាងគណបក្សសង្គ្រោះជាតិ មានទីលំនៅផ្ទះលេខ៨៤ ផ្លូវលំ សង្កាត់ ភ្នំពេញថ្មី ខណ្ឌ សែនសុខ រាជធានីភ្នំពេញ។

**សូមគោរពចូលមក**
**ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**កម្មវត្ថុ:** ប្តឹងតវ៉ាផ្ទៀងផ្ទាត់ឡើងវិញនៃទំរង់ ១១០២ និង ទំរង់ ១១០៤ នៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្ត កំពង់ធំ ចំនួន០៩ឃុំ។

**យោង:** - លិខិតលេខ៨២៦/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈ កម្មាធិការជាតិរៀបចំការបោះឆ្នោត។

- ពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣
- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម សម រង្ស៊ី។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជំរាបជូនឯកឧត្តមប្រធានមេត្តាជ្រាបថា កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ ខ្ញុំបាទ បានដាក់ពាក្យបណ្តឹងតវ៉ាទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទាមទារ:

១. តវ៉ាឲ្យផ្ទៀងផ្ទាត់ឡើងវិញលើទំរង់ ១១០២ និង ១១០៤ ចំនួន០៩ឃុំ គឺ ឃុំ ឈូកខ្សាច់ ឃុំ ក្រវ៉ា ឃុំ ដំរីស្លាប់ ឃុំ កំពង់ស្វាយ ឃុំ សាន់គរ ឃុំ ផាន់ញើម ឃុំ ញ៉ោ ឃុំ សំព្រោជ និង សង្កាត់ កំពង់រទេះ នៃការបោះឆ្នោតនៅមណ្ឌលខេត្ត កំពង់ធំ។

២. ទាមទារឲ្យរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតខេត្ត កំពង់ធំឡើងវិញដោយហេតុថា ប្រជាពលរដ្ឋបាត់ឈ្មោះជាច្រើន និង ខ្លះទៀតត្រូវគេបោះជំនួស។

ខ្ញុំបាទធ្វើការតវ៉ាយ៉ាងនេះដោយសំអាងថា:

១. នៅមណ្ឌលខេត្ត កំពង់ធំ ទាំងមូល មានប្រជាពលរដ្ឋជាច្រើនបាត់ឈ្មោះពីបញ្ជីបោះឆ្នោតឆ្នាំ២០១២ ដោយមិនដឹងពីមូលហេតុច្បាស់លាស់និង ប្រជាពលរដ្ឋជាច្រើនត្រូវគេបោះជំនួសនៅថ្ងៃបោះឆ្នោត។

២.នៅស្ទើតែគ្រប់ការិយាល័យទូទាំងខេត្ត កំពង់ធំមានការក្លែងបន្លំតួលេខលើទំរង់១១០៤ គឺតួលេខដែលបង្ហាញនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៣ ខុសពីតួលេខលើទំរង់១១០៤ដែលគណបក្ស សង្គ្រោះជាតិទទួលបាន។

ក្រោយពីបានដាក់ពាក្យបណ្តឹងមក នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានសម្រេចបដិសេធពាក្យបណ្តឹងរបស់ខ្ញុំ។

ខ្ញុំបាទមិនសុខចិត្តនឹងការសម្រេចបដិសេធពាក្យបណ្តឹងរបស់ខ្ញុំចោលនេះទេ។

អាស្រ័យហេតុនេះ សូមឯកឧត្តមប្រធាន មេត្តាទទួលយកនូវពាក្យបណ្តឹងតវ៉ារបស់ខ្ញុំបាទ ដើម្បីដោះស្រាយតាមនីតិវិធី ដោយសេចក្តីអនុគ្រោះ។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣

**ហត្ថលេខា**

*សូមជូនភ្ជាប់មកជាមួយនូវឯកសារថតចម្លង*

- *លិខិតលេខ៨២៦/១៣* *ចំនួន០១ច្បាប់។*
- *ពាក្យបណ្តឹង* *ចំនួន០១ច្បាប់។*
- *លិខិតផ្ទេរសិទ្ធិ* *ចំនួន០១ច្បាប់។*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**អគ្គលេខាធិការដ្ឋាន**

លេខ ៖ ១១០/២០១៣ អ.កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៣

**សូមគោរពជូន**

**ឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល**

**កម្មវត្ថុ** ៖ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១៣០/០០៥/២០១៣ កបធ.សសរ.ច ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៣ ។

**យោង** ៖ មាត្រា ៣៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន ឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល មេត្តាជ្រាបថា ក្នុងសវនាការជំនុំជម្រះជាសាធារណៈ នាថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៣ វេលាម៉ោង ៨ និង ៣០នាទី ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យនិងសម្រេចលើពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់លោក **កែវ តិរម្យ** តំណាងឲ្យឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលក្រចេះ និងបានចេញជាសេចក្តីសម្រេច ដូចមានជូនភ្ជាប់មកជាមួយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាលមេត្តាជ្រាប និងចាត់ការបន្តតាមការគួរ ។

សូមឯកឧត្តមអគ្គលេខាធិការ មេត្តាទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ ។

**អគ្គលេខាធិការ**

**តាន់ រ៉ាស៊ី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២២៦/០៣០/២០១៣

ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៣០/០០៥/២០១៣ កបធ.ច

ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចលេខ ០១៩/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ របស់លោក **កែវ ភីរម្យ** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តក្រចេះ
- បានឃើញលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ផ្ទេរសិទ្ធិជូនលោក **កែវ ភីរម្យ** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញទៅតាមនីតិវិធីច្បាប់
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៨៥៤/១៣ គ.ជ.ប ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់លោក **កែវ ភីរម្យ** កាលពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០១៣
- បានឃើញសេចក្តីសម្រេចលេខ ២៨/២០១៣ កបធ.សសរ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ០៤៣/២០១៣ កបធ.ច ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ២០១៣ ចាត់តាំងសមាជិកក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីចូលរួមស្រាវជ្រាវ ស៊ើបអង្កេតការបើកកញ្ចប់សុវត្ថិភាព " ក " នៅទីស្តីការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញកំណត់ហេតុស្តីពីការផ្ទៀងផ្ទាត់កញ្ចប់សុវត្ថិភាព " ក " មួយចំនួននៅមណ្ឌលខេត្តក្រចេះ នៅឃុំស្វាយជ្រះ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ២០១៣
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៨៩៥/១៣ គ.ជ.ប ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១៣
- បានឃើញលិខិតប្រគល់សិទ្ធិជាមេធាវីតំណាងដោយអាណត្តិចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១៣ របស់លោក **កែវ ភីរម្យ** ប្រគល់សិទ្ធិជូនលោកមេធាវី **ជួង ជូងី** និង លោកមេធាវី **កែត ឃី** ដើម្បីការពារនូវ

សិទ្ធិ និង ផលប្រយោជន៍ស្របច្បាប់របស់គណបក្សសង្គ្រោះជាតិ នៅចំពោះមុខក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងសំណុំរឿងលេខ ២២៦/០៣០/២០១៣ ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣

- បានឃើញលិខិតតំណាងដោយអាណត្តិចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០១៣ របស់លោកមេធាវី **ជួង ជូងី** និងពាក្យសុំតំណាងដោយអាណត្តិចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០១៣ របស់លោកមេធាវី **កែត ឃី** ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា បណ្តឹងរបស់លោក ***កែវ ភីរម្យ*** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ វេលាម៉ោង ១០ និង ៣០ នាទី ជាបណ្តឹងស្ថិតក្នុងអំឡុងពេល ៧២ ម៉ោង បន្ទាប់ពីបានទទួលសេចក្តីសម្រេចលេខ ០១៩/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៣ ។ អនុលោមតាមមាត្រា ១១៩ ថ្មី មាត្រា ១១៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ចំណុចទី២ នៃមាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូចនេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្តឹងរបស់លោក ***កែវ ភីរម្យ*** មកពិនិត្យបាន
- យល់ឃើញថា លោក ***កែវ ភីរម្យ*** នៅក្នុងពាក្យបណ្តឹងក៏ដូចជានៅចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ នាថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០១៣ បានឆ្លើយបំភ្លឺថា មានប្រជាពលរដ្ឋជាច្រើនបានបាត់ឈ្មោះពីបញ្ជីបោះឆ្នោតឆ្នាំ២០១២ ដោយមិនដឹងពីមូលហេតុ មានការកែតួលេខសន្លឹកឆ្នោតមិនបានការ ។ នៅឃុំដីផុង សន្លឹកឆ្នោតមិនបានការ ចំនួន ៩៤ សន្លឹក ឃុំកំពង់ដីរ មានសន្លឹកឆ្នោតមិនបានការរហូតដល់ ១១១ សន្លឹក និង ឃុំវឌ្ឍនៈ ប្រធានការិយាល័យបោះឆ្នោតឱ្យត្រាខុសទៅបោះលើសន្លឹកឆ្នោត ដោយយកត្រាការិយាល័យទៅបោះ ដែលខុសនឹងបទបញ្ជា និង នីតិវិធីនៃការបោះឆ្នោត ។ លោក ***កែវ ភីរម្យ*** សំណូមពរឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបើកកញ្ចប់សុវត្ថិភាព "ក" ដើម្បីផ្ទៀងផ្ទាត់ការរាប់សន្លឹកឆ្នោតឡើងវិញ
- យល់ឃើញថា នៅពេលសវនាការជំនុំជម្រះជាសាធារណៈ លោកមេធាវី **កែត ឃី** និង លោកមេធាវី **ជួង ជូងី** តំណាងដោយអាណត្តិឱ្យលោក ***កែវ ភីរម្យ*** ព្រមទាំងលោក ***កែវ ភីរម្យ*** បានបញ្ជាក់អំពីកម្មវត្ថុនៃបណ្តឹងតវ៉ានេះ គឺ : ១-ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំង

តំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តក្រចេះ ២-បដិសេធសេចក្តីសម្រេចលេខ ០១៩/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ដើមបណ្តឹង និងលោកមេធាវីទាំងពីររូបបានលើកមូលហេតុនៃការប្តឹងតវ៉ានេះដូចតទៅ ៖

១-ប្រជាពលរដ្ឋបាត់ឈ្មោះពីបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១២ ដ៏ច្រើនលើសលប់ ។

២-នៅឃុំស្វាយជ្រះ មានការក្លែងបន្លំតួលេខលើទម្រង់ ១១០៤ ចំនួន ១៣ ការិយាល័យ គឺ ការិយាល័យលេខ ០២៩៥ ០៣៦៨ ០២៧៦ ០២៦០ ០២៧៧ ០៤២៤ ០២៦១ ០២៧៨ ០២៦២ ០៣៧៤ ០២៦៣ ០៣៤៥ ០៤០៧ ។ ទម្រង់ ១១០៤ ដែលគណបក្សសង្គ្រោះជាតិទទួលបានកាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១៣ គឺខុសពីទម្រង់ ១១០៤ តួលេខដែល គឃ/ឃប បានបង្ហាញកាលពីថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០១៣ ។

៣-នៅឃុំដីវផុង ការិយាល័យលេខ ០០១១ មានសន្លឹកឆ្នោតមិនបានការ ៩៤ សន្លឹក ដែលមានការសង្ស័យ ។

៤-នៅឃុំកំពុងដីរ ការិយាល័យលេខ ០០២៤ មានសន្លឹកឆ្នោតមិនបានការ ១១១ សន្លឹក ដែលមានការសង្ស័យ ។

៥-នៅឃុំវឌ្ឍនៈ ការិយាល័យលេខ ០២៩២ មានសន្លឹកឆ្នោតទាំងអស់ត្រូវបានបោះត្រាខុស គឺប្រធានការិយាល័យប្រគល់ត្រាការិយាល័យទៅបោះលើសន្លឹកឆ្នោត ខុសនីតិវិធីដែលត្រូវប្រើត្រា ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតប្រគល់ឱ្យប្រើសម្រាប់បោះលើសន្លឹកឆ្នោត ។

នៅក្នុងរឿងនេះ លោក កែវ ភិរម្យ មានសំណូមពរដូចខាងក្រោម :

១-ទាមទារឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បង្ហាញហេតុផលដែលប្រជាពលរដ្ឋបាត់ឈ្មោះពីបញ្ជីបោះឆ្នោតឆ្នាំ២០១២ ច្រើនយ៉ាងនេះ ។

២-ទាមទារឱ្យរាប់សន្លឹកឆ្នោតឡើងវិញ នៅការិយាល័យទាំង ១៣ នៅឃុំស្វាយជ្រះ ។

៣-ទាមទារឱ្យរាប់សន្លឹកឆ្នោតឡើងវិញ នៅឃុំដីវផុង ការិយាល័យលេខ ០០១១ ។

៤-ទាមទារឱ្យរាប់សន្លឹកឆ្នោតឡើងវិញ នៅឃុំកំពង់ដីរ ការិយាល័យលេខ ០០២៤ ។

៥-ទាមទារឱ្យរាប់សន្លឹកឆ្នោតឡើងវិញ នៅឃុំវឌ្ឍនៈ ការិយាល័យលេខ ០២៩២ ។

- យល់ឃើញថា ឯកឧត្តម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ក៏ដូចជានៅពេលសវនាការជាសាធារណៈ បានបញ្ជាក់ថា ការប្តឹងតវ៉ាពីការបាត់ឈ្មោះត្រូវធ្វើឡើងក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និង ការចុះឈ្មោះ

បោះឆ្នោត គឺចាប់ពីថ្ងៃទី ០១ ខែ តុលា រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ជារៀងរាល់ឆ្នាំ ។ នៅឆ្នាំដែលមានការបោះឆ្នោតសកល ដូចជាឆ្នាំ២០១៣ នេះ ការពិនិត្យបញ្ជីឈ្មោះនិងការចុះឈ្មោះបោះឆ្នោតបានចាប់ធ្វើពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១២ គឺធ្វើមុនមួយខែ ដែលមានចែងក្នុងប្រតិទិនរបស់គណៈ-កម្មាធិការជាតិរៀបចំបោះឆ្នោត ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១២ ស្របតាមបទប្បញ្ញត្តិនៃមាត្រា ៤៩ ថ្មី ( បី ) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ។ បណ្តឹងតវ៉ា ឬ ជំទាស់នឹងការបាត់ឈ្មោះ លុបឈ្មោះ និង ការចុះឈ្មោះបោះឆ្នោត បានផុតអាជ្ញាយុកាលតាំងពីខែ ធ្នូ ឆ្នាំ២០១២ ។ នៅឃុំដីផុង ការិយាល័យបោះឆ្នោតលេខ ០០១១ មានសន្លឹកឆ្នោតមិនបានការចំនួន ៩៤ សន្លឹក និង ឃុំកំពង់ដីរ ការិយាល័យបោះឆ្នោតលេខ ០០២៤ មានសន្លឹកឆ្នោតមិនបានការចំនួន ១១១ សន្លឹក ពុំមានភស្តុតាងមកបញ្ជាក់ឱ្យបានច្បាស់លាស់ទេ ។ ដើមបណ្តឹងមិនបានបញ្ជាក់ពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬ សមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និង អាសយដ្ឋាននៃសាក្សីព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀត ស្របតាមបទប្បញ្ញត្តិនៃមាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ គ្រប់កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតលើទម្រង់ ១១០២ ទម្រង់ ១១០៨ និងក្រដាសធំកត់ត្រាសំឡេងឆ្នោតតាមការិយាល័យបោះឆ្នោត និង រាប់សន្លឹកឆ្នោតនីមួយៗ សុទ្ធតែមានចុះហត្ថលេខាលើកំណត់ហេតុទទួលស្គាល់ពីតំណាងគណបក្សនយោបាយ

- យល់ឃើញថា ពេលបើកកញ្ចប់សុវត្ថិភាព "ក" ចំនួន ១៣ ការិយាល័យនៅឃុំស្វាយជ្រះ តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ មានកញ្ចប់សុវត្ថិភាព "ក" ចំនួន ៨ ការិយាល័យ មិនបិទភ្ជិតដោយការសុវត្ថិភាព គឺជាភាពមិនប្រក្រតី ប៉ុន្តែកញ្ចប់សុវត្ថិភាព "ក" ទាំងអស់នេះ បានរក្សាទុកនៅក្នុងកញ្ចប់ "ខ" បិទភ្ជិតនិងចាក់សោឃ្លុំមានកត់ត្រាលេខ នៅចំពោះមុខតំណាងគណបក្សនយោបាយ និង អ្នកសង្កេតការណ៍ បន្ទាប់មកបញ្ជូនទៅ គឃ/សប គឃ/សប កាត់សោឃ្លុំចេញនៅចំពោះមុខតំណាងគណបក្សនយោបាយ និង អ្នកសង្កេតការណ៍ ហើយចងមាត់ បន្ទាប់មកយកកញ្ចប់ "ខ" ទៅដាក់ក្នុងកញ្ចប់ "គ" ដោយសរសេរសម្គាល់ពីក្រៅ ដោយបិទហ្វីតលុបមិនជ្រះ នូវលេខកូដឃុំ សង្កាត់ និង លេខកូដការិយាល័យ ចងភ្ជិត និង ចាក់សោឃ្លុំមានលេខ នៅចំពោះមុខតំណាងគណបក្សនយោបាយ និង អ្នកសង្កេតការណ៍ រួចហើយបញ្ជូនកញ្ចប់ "គ" ទៅ គធ/ខប គធ/ខប យកកញ្ចប់ "គ" ទៅដាក់ក្នុងកញ្ចប់ "ឃ" ចងមាត់ចាក់សោឃ្លុំព្រមទាំងកត់ត្រាលេខសោនៅចំពោះមុខតំណាងគណបក្សនយោបាយ និង អ្នកសង្កេតការណ៍
- យល់ឃើញថា ការមិនបកប្លាស្ទិកថ្លាចេញ ធ្វើឱ្យកញ្ចប់សុវត្ថិភាព "ក" ចំហរ ជាកំហុសរបស់មន្ត្រីការិយាល័យបោះឆ្នោត និង រាប់សន្លឹកឆ្នោតទាំង ៨ ការិយាល័យ ។ មន្ត្រីដែលធ្វើការងារនោះផ្ទាល់នៅការិយាល័យ

ទាំង ៨ ការិយាល័យនេះត្រូវទទួលទណ្ឌកម្មតាមច្បាប់កំណត់ ។ ដោយឡែកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលជាអាណាព្យាបាលពីលើក៏ត្រូវទទួលខុសត្រូវខាងសីលធម៌អំពីការងារគ្រប់គ្រងរបស់ខ្លួន ។ ក្រោយពីការពិនិត្យផ្ទៀងផ្ទាត់សំឡេងឆ្នោតក្នុងកញ្ចប់សុវត្ថិភាព "ក" ទាំង ១៣ ការិយាល័យនៅឃុំស្វាយជ្រះ ឃើញថាសំឡេងឆ្នោតរបស់គណបក្សសង្គ្រោះជាតិ និង សំឡេងឆ្នោតរបស់គណបក្សប្រជាជនកម្ពុជា ក្នុងទម្រង់ ១១០២ ទម្រង់ ១១០៨ និង ក្រដាសធំកត់ត្រាសំឡេងឆ្នោត មិនមានការប្រែប្រួលទេ ។ សូមអានឧបសម្ព័ន្ធស្តីពីកំណត់ហេតុនៃការបើកកញ្ចប់សុវត្ថិភាព "ក" ១៣ ការិយាល័យនៅឃុំស្វាយជ្រះ

- យល់ឃើញថា ជាចុងក្រោយ លោក **កែវ ភីរម្យ** និង លោកមេធាវីទាំងពីររូប បានលើកសំណូមពរចំនួន ៤ ចំណុច ៖

១-បដិសេធសេចក្តីសម្រេចលេខ ០១៩/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចោលទាំងស្រុង ។

២-អនុញ្ញាតឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតធ្វើការរាប់សន្លឹកឆ្នោតបានការ និង ផ្ទៀងផ្ទាត់ឡើងវិញលើសន្លឹកឆ្នោតមិនបានការទូទាំងខេត្តក្រចេះទាំងមូល ។

៣-ចាត់ឱ្យមានការស៊ើបអង្កេតឡើងវិញ ថាតើកំហុសទាំងអស់ខាងលើនេះ មានការបង្កាប់បញ្ជាពីត្រឹមថ្នាក់ណា ? ត្រឹមថ្នាក់សមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ឬថ្នាក់សមាជិកគណៈកម្មការខេត្ត ក្រុង ឃុំ សង្កាត់រៀបចំការបោះឆ្នោត ឬ ពីថ្នាក់សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះទៅ ។

៤-សុំឱ្យមានការផ្តន្ទាទោសលើជនប្រព្រឹត្តល្មើស តាមមាត្រា ១២៥ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនិងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- យល់ឃើញថា ឯកឧត្តម **ម៉ៅ សុភារិទ្ធ** នៅពេលសវនាការជាសាធារណៈបានបំភ្លឺបន្ថែមថា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបំពេញសមត្ថកិច្ចស្របតាមច្បាប់ និង បទបញ្ជានិងនីតិវិធី ។ ក្រោយពីបានឃើញលទ្ធផលនៃការបើកកញ្ចប់សុវត្ថិភាព "ក" ចំនួន ១៣ ការិយាល័យនៅឃុំស្វាយជ្រះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានចាត់តាំងមន្ត្រីក្រុមសេវាកម្មច្បាប់របស់ខ្លួនឱ្យចុះទៅធ្វើការត្រួតពិនិត្យ ។ លទ្ធផលនៃការត្រួតពិនិត្យត្រូវបានលោក **កែវ ផល្លា** អានជូនអង្គសវនាការជាសាធារណៈទាំងស្រុង ។ ជាចុងក្រោយបង្អស់ ឯកឧត្តម **ម៉ៅ សុភារិទ្ធ** បានសំណូមពរសុំតម្កល់សេចក្តីសម្រេចលេខ ០១៩/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៣ ទុកជាបានការពេញទាំងមូល

- យល់ឃើញថា កំហុសរបស់មន្ត្រីការិយាល័យបោះឆ្នោត និង រាប់សន្លឹកឆ្នោតទាំង ៨ ការិយាល័យនៅឃុំស្វាយជ្រះ ត្រូវទទួលទណ្ឌកម្មស្របតាមច្បាប់កំណត់
- យល់ឃើញថា សេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០១៩/១៣ គ.ជ.ប. ស.ស.រ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៣ មានមូលហេតុ ព្រមទាំងធ្វើឡើងស្របតាមទម្រង់ និង គតិច្បាប់ លើកលែងតែមន្ត្រីការិយាល័យបោះឆ្នោត និង រាប់សន្លឹកឆ្នោតក្នុងការិយាល័យទាំង ៨ នៃឃុំស្វាយជ្រះ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមិនបានលើកឡើង
- យល់ឃើញថា ការបោះឆ្នោតនៅមណ្ឌលខេត្តក្រចេះពុំមានអំពើហិង្សា និង ពុំមានចលាចលវឹកវរទេ ។ ប្រជាពលរដ្ឋក្នុងមណ្ឌលបានទៅបោះឆ្នោតដោយសម្ងាត់ និង ដោយសេរីដែលមានអត្រា ៦៨,៦៣% ។

## សម្រេច

## ចំពោះមុខគូភាគី

**មាត្រា ១.-** ទទួលពាក្យបណ្ដឹងរបស់លោក **កែវ ភីរម្យ** ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្ដីសម្រេចលេខ ០១៩/១៣ គ.ជ.ប. ស.ស.រ ចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទុកជាបានការ ប៉ុន្តែសេចក្ដីសម្រេចនេះមិនបានចាត់វិធានការលើមន្ត្រីការិយាល័យបោះឆ្នោត និង រាប់សន្លឹកឆ្នោតទាំង ៨ នៅឃុំស្វាយជ្រះដែលបានប្រព្រឹត្តខុស ។

**មាត្រា ៣.-** ប្រគល់ភារកិច្ចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចាត់វិធានការដាក់ទណ្ឌកម្មលើមន្ត្រីដែលប្រព្រឹត្តខុសដូចមានចែងក្នុងមាត្រា ២ ។

**មាត្រា ៤.-** សេចក្ដីសម្រេចនេះ ប្រកាសនាសវនាការជាសាធារណៈ នៅរាជធានីភ្នំពេញថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៣ ជាសេចក្ដីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០១៣

**ជ. ក្រុមប្រឹក្សាធម្មនុញ្ញ និង ជ. ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សិរីវុឌ្ឍ**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

ឧបសម្ព័ន្ធនៃសេចក្តីសម្រេច

លេខ ១៣០/០០៥/២០១៣ កបធ.ច

ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៣

## កំណត់ហេតុ

ស្តីពី

## ការផ្ទៀងផ្ទាត់កញ្ចប់សុវត្ថិភាព "ក" មួយចំនួន នៅមណ្ឌលខេត្តក្រចេះ នៅឃុំស្វាយជ្រះ

- យោងសេចក្តីសម្រេចលេខ ២៨/២០១៣.កបធ.សសរ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាធម្មនុញ្ញ
- យោងលិខិតបង្គាប់ការលេខ ៨៧៨/១៣ គ.ជ.ប ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ឆ្នាំពីរពាន់ដប់បី ខែសីហា ថ្ងៃអាទិត្យ ទីម្ភៃប្រាំ វេលាម៉ោងប្រាំពីរ និងសែសិបនាទីព្រឹក នៅសាលសន្និសីទនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានការបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តក្រចេះ នៅការិយាល័យបោះឆ្នោតលេខ ០២៥៩ ០២៦០ ០២៦១ ០២៦២ ០២៦៣ ០២៧៦ ០២៧៧ ០២៧៨ ០៣៥៥ ០៣៦៨ ០៣៧៨ ០៤០៧ និង ០៤២៨ នៅឃុំស្វាយជ្រះ ដើម្បីផ្ទៀងផ្ទាត់ ក្រោមការត្រួតពិនិត្យរបស់ក្រុមស៊ើបអង្កេតក្រុមប្រឹក្សាធម្មនុញ្ញ។

ជាកិច្ចចាប់ផ្តើម ក្រុមត្រួតពិនិត្យនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានជម្រាបអំពីនីតិវិធីនៃការត្រួតពិនិត្យផ្ទៀងផ្ទាត់ និងយាង និងអញ្ជើញតំណាងក្រុមប្រឹក្សាធម្មនុញ្ញ តំណាងគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ អ្នកសារព័ត៌មានជាតិ អន្តរជាតិ ចូលរួមពិនិត្យការបើកកញ្ចប់សុវត្ថិភាព "ក" មួយចំនួននៅមណ្ឌលខេត្តក្រចេះ នៅការិយាល័យបោះឆ្នោតលេខ ០២៥៩ ០២៦០ ០២៦១ ០២៦២ ០២៦៣ ០២៧៦ ០២៧៧ ០២៧៨ ០៣៥៥ ០៣៦៨ ០៣៧៨ ០៤០៧ និង ០៤២៨ នៅឃុំស្វាយជ្រះ ដើម្បីផ្ទៀងផ្ទាត់។ ក្រុមត្រួតពិនិត្យបានធ្វើការបើកកញ្ចប់សុវត្ថិភាព "ក" ធ្វើការផ្ទៀងផ្ទាត់ម្តងមួយការិយាល័យនៅចំពោះមុខតំណាងក្រុមប្រឹក្សាធម្មនុញ្ញ គណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ អន្តរជាតិ អ្នកសារព័ត៌មានជាតិ អន្តរជាតិ។

មុននឹងចាប់ផ្តើមដំណើរការផ្ទៀងផ្ទាត់ឯកឧត្តម គួយ ប៊ុនរឿន តំណាងគណបក្សសង្គ្រោះជាតិ បានស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញរៀបចំយន្តការ និងនីតិវិធីផ្ទៀងផ្ទាត់ និងត្រួតពិនិត្យសម្ភារឯកសារបោះឆ្នោត និង

សន្លឹកឆ្នោតនៅការិយាល័យទាំង ១៣នោះ ជាមុនសិន ទើបយកទម្រង់បែបបទលេខ ១១០២ ១១០៨ និងក្រដាសផ្ទាំងគូសសន្លឹកឆ្នោតមកពិនិត្យ និងផ្ទៀងផ្ទាត់ជាបន្ទាប់។

ឯកឧត្តម ព្រហ្ម ញាណវិចិត្រ តំណាងក្រុមប្រឹក្សាធម្មនុញ្ញ បានលើកឡើងថា ការត្រួតពិនិត្យនៅថ្ងៃនេះ ត្រូវអនុវត្តតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ហើយឯកឧត្តមបានសម្រេចឲ្យបន្តនីតិវិធីត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ដោយទទួលបានលទ្ធផលដូចខាងក្រោម ៖

## ការិយាល័យលេខកូដ ០២៥៩

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ជាតិកម្ពុជា | ០៧ | ០៨ | ០៧ | ១១០៨ លើស ០១សន្លឹក |
| ២-ហ៊្វុនស៊ិនប៉ិច | ៨០ | ៨០ | ៨០ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ១៥ | ១៥ | ១៥ | |
| ៤-ប្រជាជនកម្ពុជា | ១៩០ | ១៩០ | ១៩០ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ១៦ | ១៦ | ១៦ | |
| ៧-សង្គ្រោះជាតិ | ១៧១ | ១៧១ | ១៧១ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ១៣ | ១៣ | ១៣ | |

<u>ការកត់សម្គាល់ភាពមិនប្រក្រតី របស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម កែវ ភីរម្យ ៖

- កញ្ចប់សុវត្ថិភាព "ក" ពុំមានបិទការសុវត្ថិភាព
- ស្រោមសំបុត្រដាក់ទម្រង់បែបបទមិនមានបិទការ។
- ទម្រង់លេខ ១១០៤ គណបក្សសង្គ្រោះជាតិទទួលបាន ៨០១សំឡេងបានការ ប៉ុន្តែ គជ/ខបបែរទទួលបានរហូតដល់ ៨៥២សំឡេង សន្លឹកឆ្នោតបានការនៅក្នុងទម្រង់ ១១០៤ គណបក្សសង្គ្រោះជាតិ ទទួលបាន ៧៨សន្លឹក ប៉ុន្តែ គជ/ខប កត់ត្រាតួលេខមក ២៣សំឡេងវិញ។

## ការិយាល័យលេខកូដ ០២៦០

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ជាតិកម្ពុជា | គ្មាន | ០៥ | ០៥ | ១១០២ មិនបំពេញទិន្នន័យ |
| ២-ហ៊្វុនស៊ិនប៉ិច | ៣១ | ៣១ | ៣១ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | គ្មាន | ០៤ | ០៤ | ១១០២ មិនបំពេញទិន្នន័យ |
| ៤-ប្រជាជនកម្ពុជា | ២១០ | ២១០ | ២១០ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | គ្មាន | ០២ | ០២ | ១១០២ មិនបំពេញទិន្នន័យ |

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ៧-សង្គ្រោះជាតិ | ២០៤ | ២០៤ | ២០៤ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | គ្មាន | ០២ | ០២ | ១១០២ មិនបំពេញទិន្នន័យ |

ការកត់សម្គាល់ភាពមិនប្រក្រតី របស់តំណាងគណបក្សសង្គ្រោះជាតិ ៖

ឯកឧត្តម កែវ ភិរម្យ ៖

- កញ្ចប់សុវត្ថិភាព "ក" ពុំមានបិទការសុវត្ថិភាព
- ស្រោមសំបុត្រដាក់ទម្រង់បែបបទមិនមានបិទការ។

ឯកឧត្តម គួយ ប៊ុនរឿន ៖

- គំរូហត្ថលេខារបស់តំណាងគណបក្សសង្គ្រោះជាតិឃើញថា ត្រឹមត្រូវ។
- តាមទម្រង់លេខ ១១០៤ គណបក្សសង្គ្រោះជាតិទទួលបានចំនួន ៤៥៥សំឡេង ប៉ុន្តែ គធ/ខប កត់ត្រាមានចំនួន ៥៥៨សន្លឹកវិញ។
- សន្លឹកឆ្នោតមិនបានការក្នុងទម្រង់ ១១០៤ គណបក្សសង្គ្រោះជាតិទទួលបានមានចំនួន ២២ សន្លឹក ប៉ុន្តែ គធ/ខប កត់ត្រាមានតែចំនួន ០៩សន្លឹកវិញ។

## ការិយាល័យលេខកូដ ០២៦១

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០៨ | ០៨ | ០៨ | |
| ២-ហ្វ៊ុនស៊ិនប៉ិច | ៣៧ | ៣៧ | ៣៧ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ១០ | ១០ | ១០ | |
| ៤-ប្រជាជនកម្ពុជា | ១៤៨ | ១៤៨ | ១៤៨ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ១១ | ១១ | ១១ | |
| ៧-សង្គ្រោះជាតិ | ២១៧ | ២១៧ | ២១៧ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ១៦ | ១៦ | ១៦ | |

ការកត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- កញ្ចប់សុវត្ថិភាព "ក" ពុំបានបិទការសុវត្ថិភាព។
- គណបក្សតូចៗមិនមានបំពេញទិន្នន័យទេ មានតែគណបក្ស ០៣ គឺគណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិ និងគណបក្សហ្វ៊ុនស៊ិនប៉ិច។ ទម្រង់ ១១០៤ គណបក្សទទួលមានសន្លឹកឆ្នោតបានការ ៤០២សំឡេង មិនបានការ ៥០សំឡេង ប៉ុន្តែទម្រង់ ១១០៤ ដែលគណបក្សសង្គ្រោះជាតិទទួលបាននៅ គឃ/សប និង គធ/ខប សន្លឹកឆ្នោតបានការ ៤៤៧សំឡេង សន្លឹកឆ្នោតមិនបានការ ០៥សំឡេងវិញ។

## ការិយាល័យលេខកូដ ០២៦២

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០៨ | ០៨ | ០៨ | |
| ២-ហ្វ៊ុនស៊ិនប៉ិច | ៣៨ | ៣៨ | ៣៨ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ១២ | ១២ | ១២ | |
| ៤-ប្រជាជនកម្ពុជា | ១៨៥ | ១៨៥ | ១៨៥ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០៩ | ០៩ | ០៩ | |
| ៧-សង្គ្រោះជាតិ | ១៩៩ | ១៩៩ | ១៩៩ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៨ | ០៨ | ០៨ | |

<u>ការកត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- កញ្ចប់សុវត្ថិភាព "ក" ពុំបានបិទការសុវត្ថិភាព។
- គណបក្សតូចៗមិនមានបំពេញទិន្នន័យទេ មានតែគណបក្ស ០៣ គឺគណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិ និងគណបក្សហ្វ៊ុនស៊ិនប៉ិច។ ទម្រង់ ១១០៤ គណបក្សសង្គ្រោះជាតិទទួលបានមានសន្លឹកឆ្នោតបានការ ៤២២សំឡេង សន្លឹកឆ្នោតមិនបាន ៨៦សំឡេង។ ទម្រង់ ១១០៤ ដែល គជ/ខប បានបង្ហាញមានសន្លឹកឆ្នោតបានការ ៤៥៩សំឡេង សន្លឹកឆ្នោតមិនបានការ ០៩សំឡេង។

## ការិយាល័យលេខកូដ ០២៦៣

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០៧ | ០៧ | ០៧ | |
| ២-ហ្វ៊ុនស៊ិនប៉ិច | ២៧ | ២៧ | ២៧ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០៦ | ០៦ | ០៦ | |
| ៤-ប្រជាជនកម្ពុជា | ១៧៩ | ១៧៩ | ១៧៩ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០២ | ០២ | ០២ | |
| ៧-សង្គ្រោះជាតិ | ១២៣ | ១២៣ | ១២៣ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០២ | ០២ | ០២ | |

<u>ការកត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- កញ្ចប់សុវត្ថិភាព "ក" បិទការសុវត្ថិភាព។
- គណបក្សតូចៗមិនមានបំពេញទិន្នន័យទេ មានតែគណបក្ស ០៣ គឺគណបក្សប្រជាជនកម្ពុជា គណបក្សសង្គ្រោះជាតិ និងគណបក្សហ៊្វុនស៊ិនប៉ិច។ ទម្រង់ ១១០៤ ដែលគណបក្សសង្គ្រោះជាតិទទួលបានមានសន្លឹកឆ្នោតបានការ ៣២៩សំឡេង, សន្លឹកឆ្នោតមិនបានការ ២៧សំឡេង។ ទម្រង់ ១១០៤ ដែល គជ/ខប បានបង្ហាញមានសន្លឹកឆ្នោតបានការ ៣៤៦សំឡេង សន្លឹកឆ្នោតមិនបានការ ១០សំឡេង។

## ការិយាល័យលេខកូដ ០២៧៦

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៤ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ជាតិកម្ពុជា | ១០ | ១០ | គ្មាន | ក្រដាសកត់ត្រាមិនបានកត់ត្រា |
| ២-ហ៊្វុនស៊ិនប៉ិច | ៣០ | ៣០ | ៣០ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០៨ | ០៨ | គ្មាន | ក្រដាសកត់ត្រាមិនបានកត់ត្រា |
| ៤-ប្រជាជនកម្ពុជា | ២០១ | ២០១ | ២០១ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០៦ | ០៦ | គ្មាន | ក្រដាសកត់ត្រាមិនបានកត់ត្រា |
| ៧-សង្គ្រោះជាតិ | ១២៦ | ១២៦ | ១២៦ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៩ | ០៩ | គ្មាន | ក្រដាសកត់ត្រាមិនបានកត់ត្រា |

<u>ការកត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- កញ្ចប់សុវត្ថិភាព "ក" បិទការសុវត្ថិភាព។
- គំរូហត្ថលេខាតំណាងគណបក្សសង្គ្រោះជាតិ ឃើញថា ត្រឹមត្រូវ។

ឯកឧត្តម កែវ ភីរម្យ ៖

- ទម្រង់ ១១០៤ គណបក្សសង្គ្រោះជាតិបានទទួលមានសន្លឹកឆ្នោតមិនបានការ ៤៣, សន្លឹកឆ្នោតបានការសរុប ៣៥៧។ ទម្រង់ ១១០៤ ដែល គជ/ខប បានបង្ហាញមិនបានការ ១០សំឡេង សន្លឹកឆ្នោតបានការ ៣៩០សំឡេង។ ក្រដាសកត់ត្រាមិនបានបង្ហាញគណបក្សតូចៗ។

## ការិយាល័យលេខកូដ ០២៧៧

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៤ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ជាតិកម្ពុជា | ០៦ | ០៦ | ០៦ | |
| ២-ហ៊្វុនស៊ិនប៉ិច | ៧៤ | ៤៧ | ៤៧ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០៦ | ០៦ | ០៦ | |
| ៤-ប្រជាជនកម្ពុជា | ១៧៤ | ១៧៤ | ១៧៤ | |
| | | | | |

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ៦-ខ្មែរឈប់ក្រ | ០៥ | ០៥ | ០៥ | |
| ៧-សង្គ្រោះជាតិ | ១៧៩ | ១៧៩ | ១៧៩ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ១០ | ១០ | ១០ | |

<u>ការកត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម កែវ ភីរម្យ ៖

- កញ្ចប់សុវត្ថិភាព "ក" ពុំបានបិទការសុវត្ថិភាព។
- ក្រដាសកត់ត្រាសំឡេងឆ្នោតមានភាពខុសគ្នាត្រង់ថា ដោយមានសរសេរទឹកប៊ិចហ្វឺតព័ណ៌ខៀវ និងមួយព័ណ៌ខ្មៅនៅក្នុងក្រដាសតែមួយ។ គណបក្សបីមានព័ណ៌ខ្មៅ ឯគណបក្សតូចៗមួយចំនួនទៀតប្រើទឹកប៊ិចព័ណ៌ខៀវ ហើយអក្សរខុសគ្នាទៀត។

ឯកឧត្តម គួយ ប៊ុនរឿន ៖

- គណបក្សសង្គ្រោះជាតិ ទទួលបានតែ ០៣គណបក្ស គឺគណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសង្គ្រោះជាតិ។ សន្លឹកឆ្នោតបានការ ៤០០សំឡេង សន្លឹកឆ្នោតមិនបានការ ៣៥សំឡេង តែមកដល់ គឃ/សប និង គធ/ខប សន្លឹកឆ្នោតបានការកើនឡើងពី ៤០០សំឡេងទៅ ៤២៧សំឡេង សន្លឹកឆ្នោតមិនបានការថយចុះពី ៣៥សំឡេងមក ០៨ សំឡេង។
- ក្រដាសកត់ត្រាសំឡេងឆ្នោតពុំមានបូកសរុបសំឡេងឆ្នោត (ក្រុមគ្រូតពិនិត្យ គ.ជ.ប បូកបន្ថែម)។

## ការិយាល័យលេខកូដ ០២៧៨

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០៥ | ០៥ | ០៥ | |
| ២-ហ៊្វុនស៊ិនប៉ិច | ២២ | ២២ | ២២ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០៦ | ០៦ | ០៦ | |
| ៤-ប្រជាជនកម្ពុជា | ៩៨ | ៩៨ | ៩៨ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០៤ | ០៤ | ០៤ | |
| ៧-សង្គ្រោះជាតិ | ១៧៤ | ១៧៤ | ១៧៤ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៨ | ០៥ | ០៥ | |

<u>ការកត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- កញ្ចប់សុវត្ថិភាព "ក" ពុំបានបិទការសុវត្ថិភាព។
- ទម្រង់ ១១០៤ ដែលគណបក្សសង្គ្រោះជាតិបានទទួលមានសន្លឹកឆ្នោតបានការ ២៩៨សំឡេង សន្លឹកឆ្នោតមិនបានការ ២៦សំឡេង។ ទម្រង់ ១១០៤ ដែល គជ/ខប បានបង្ហាញមាន សន្លឹកឆ្នោតមានការកើនឡើងពី ២៩៨សំឡេងមក ៣១៨សំឡេង សន្លឹកឆ្នោតមិនបានការថយចុះពី ២៦សំឡេង មក ០៦សំឡេងវិញ។

ឯកឧត្តម កែវ ភីរម្យ ៖

- ក្រដាសកត់ត្រាសំឡេងឆ្នោតមានកោសលុប។

## ការិយាល័យលេខកូដ ០៣៨៥

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០២ | ០២ | ០២ | |
| ២-ហ៊្វុនស៊ិនប៉ិច | ២៦ | ២៦ | ២៦ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០៧ | ០៧ | ០៧ | |
| ៤-ប្រជាជនកម្ពុជា | ២១៥ | ២១៥ | ២១៥ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០៣ | ០៣ | ០៣ | |
| ៧-សង្គ្រោះជាតិ | ១២៨ | ១២៨ | ១២៨ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៧ | ០៧ | ០៧ | |

<u>ការកត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម កែវ ភីរម្យ ៖

- កញ្ចប់សុវត្ថិភាព "ក" ពុំបានបិទការសុវត្ថិភាព។
- ក្រដាសកត់ត្រាសំឡេងឆ្នោត មានប្រើប៊ិចហ្វឺតខុសព័ណ៌គ្នា អក្សរនៅក្នុងគណបក្សតូចៗខុសគ្នាពីអក្សរនៅក្នុងគណបក្សហ៊្វុនស៊ិនប៉ិច គណបក្សប្រជាជនកម្ពុជា និងគណបក្សសង្គ្រោះជាតិ។

ឯកឧត្តម គួយ ប៊ុនរឿន ៖

- ទម្រង់ ១១០៤ គណបក្សសង្គ្រោះជាតិបានទទួលសន្លឹកឆ្នោតបានការ ៣៦៩សំឡេង, សន្លឹកឆ្នោតមិនបានការ ៣៨សំឡេង។ ទទួលបាននៅ គឃ/សប ចំនួន ៣៨៨សំឡេង សន្លឹកឆ្នោតមិនបានការ ១៩សំឡេង។

## ការិយាល័យលេខកូដ ០៣៦៨

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០២ | ០២ | ០២ | |

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ២-ហ៊្វុនស៊ិនប៉ិច | ០៧ | ០៧ | ០៧ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០៥ | ០៥ | ០៥ | |
| ៤-ប្រជាជនកម្ពុជា | ៦២ | ៦២ | ៦២ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០៤ | ០៤ | ០៤ | |
| ៧-សង្គ្រោះជាតិ | ៧៨ | ៧៨ | ៧៨ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | គ្មាន | គ្មាន | គ្មាន | មិនបានបំពេញទិន្នន័យ |

ការកត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ ៖

ឯកឧត្តម កែវ ភីរម្យ ៖

- កញ្ចប់សុវត្ថិភាព "ក" ពុំបានបិទការសុវត្ថិភាព។
- ទម្រង់ ១១០៤ គណបក្សសង្គ្រោះជាតិ ទទួលបានថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ សន្លឹកឆ្នោតមិនបានការ ១៥សំឡេង សន្លឹកឆ្នោតបានការសរុប ១៤៧សំឡេង។ ទម្រង់ ១១០៤ ទទួលពី គធ/ខប សន្លឹកឆ្នោតមិនបានការ ០៤សំឡេង សន្លឹកឆ្នោតបានការសរុប ១៥៨សំឡេង។ តួលេខនោះបានគូសលុបនៅទម្រង់ ១១០៤ ដែល គធ/ខប បានបង្ហាញ។

## ការិយាល័យលេខកូដ ០៣៧៤

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ជាតិកម្ពុជា | ០៣ | ០៣ | ០៣ | |
| ២-ហ៊្វុនស៊ិនប៉ិច | ០៣ | ០៣ | ០៣ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០៣ | ០៣ | ០៣ | |
| ៤-ប្រជាជនកម្ពុជា | ៦២ | ៦២ | ៦២ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០៣ | ០៣ | ០៣ | |
| ៧-សង្គ្រោះជាតិ | ៦២ | ៦២ | ៦២ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០២ | ០២ | ០២ | |

ការកត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- កញ្ចប់សុវត្ថិភាព "ក" បិទការសុវត្ថិភាព។
- ទម្រង់ ១១០៤ គណបក្សសង្គ្រោះជាតិ ទទួលបានមាន ០៣គណបក្ស សន្លឹកឆ្នោតបានការ ១២៧សំឡេង សន្លឹកឆ្នោតមិនបានការ ១២សំឡេង។ ទទួលបាននៅ គយ/សប និង គធ/ខប សន្លឹកឆ្នោតបានការ ១៣៨សំឡេង សន្លឹកឆ្នោតមិនបានការ ០១សំឡេង។

## ការិយាល័យលេខកូដ ០៤០៧

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០២ | ០២ | ០២ | |
| ២-ហ៊្វុនស៊ិនប៉ិច | ០៦ | ០៦ | ០៦ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០២ | ០២ | ០២ | |
| ៤-ប្រជាជនកម្ពុជា | ៨៦ | ៨៦ | ៨៦ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០១ | ០១ | ០១ | |
| ៧-សង្គ្រោះជាតិ | ២៧ | ២៧ | ២៧ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៧ | ០៧ | ០៧ | |

<u>ការកត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- កញ្ចប់សុវត្ថិភាព "ក" បិទការសុវត្ថិភាព។
- ក្រដាសកត់ត្រាសំឡេងឆ្នោត សំឡេងឆ្នោតបានការកត់រួចហើយ លុបចោលទាំងអស់។
- ទម្រង់ ១១០៤ គណបក្សសង្គ្រោះជាតិទទួលមាន ០៣គណបក្ស សន្លឹកឆ្នោតបានការ ៧៩ សំឡេង មិនបានការ ១២សំឡេង។ បានទទួលនៅ គឃ/សប និង គជ/ខប សន្លឹកឆ្នោតបានការ ៩១សំឡេង សន្លឹកឆ្នោតមិនបានការ ០សំឡេង។

## ការិយាល័យលេខកូដ ០៤២៤

| គណបក្សឈរឈ្មោះបោះឆ្នោត | លទ្ធផលសំឡេងឆ្នោត | | | កំណត់សម្គាល់ |
|---|---|---|---|---|
| | ទម្រង់ ១១០២ | ទម្រង់ ១១០៨ | ក្រដាសកត់ត្រាសំឡេងឆ្នោត | |
| ១-សញ្ញាតិកម្ពុជា | ០៤ | ០៤ | ០៤ | |
| ២-ហ៊្វុនស៊ិនប៉ិច | ១៦ | ១៦ | ១៦ | |
| ៣-សាធារណរដ្ឋប្រជាធិបតេយ្យ | ០១ | ០១ | ០១ | |
| ៤-ប្រជាជនកម្ពុជា | ២៤០ | ២៤០ | ២៤០ | |
| | | | | |
| ៦-ខ្មែរឈប់ក្រ | ០៥ | ០៥ | ០៥ | |
| ៧-សង្គ្រោះជាតិ | ១៥៩ | ១៥៩ | ១៥៩ | |
| ៨-សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ០៤ | ០៤ | ០៤ | |

<u>ការកត់សម្គាល់ភាពមិនប្រក្រតីរបស់តំណាងគណបក្សសង្គ្រោះជាតិ</u> ៖

ឯកឧត្តម គួយ ប៊ុនរឿន ៖

- កញ្ចប់សុវត្ថិភាព "ក" បិទការសុវត្ថិភាព។
- ទម្រង់ ១១០៤ គណបក្សសង្គ្រោះជាតិ បានទទួលមានតែ ០៣គណបក្ស គឺគណបក្សប្រជាជនកម្ពុជា គណបក្សហ៊្វុនស៊ិនប៉ិច និងគណបក្សសង្គ្រោះជាតិ។ ក្នុងនោះសន្លឹកឆ្នោតបានការ ៤១៥សំឡេង សន្លឹកឆ្នោតមិនបានការ ២៣សំឡេង។ ទម្រង់ ១១០៤ ទទួលបានពី គជ/ខប សន្លឹកឆ្នោតបានការកើនឡើងដល់ ៤២៩សំឡេង សន្លឹកឆ្នោតមិនបានការ ២៣សំឡេង ថយចុះមក ០៩សំឡេង។

ការផ្ទៀងផ្ទាត់បានបញ្ចប់នៅវេលាម៉ោងដប់មួយ និងសាមសិបនាទីនាថ្ងៃខែឆ្នាំដដែល។

**តំណាងក្រុមប្រឹក្សាធម្មនុញ្ញ**

ឯកឧត្តម ព្រហ្ម ញាណវិចិត្រ..........

អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ ផាន់ដារ៉ាវង្ស..........

ឯកឧត្តម មឹន ស៊ាន..........

**ក្រុមលេខាកត់ត្រាក្រុមប្រឹក្សាធម្មនុញ្ញ**

កញ្ញា សារិន សច្ចជា..........

លោក នុត យុទ្ធនា..........

លោក តាន់ ម៉ាឡា..........

**តំណាងគណបក្សនយោបាយ**

**តំណាងគណបក្សសង្គ្រោះជាតិ ៖**

ឯកឧត្តម កែវ ភីរម្យ..........

ឯកឧត្តម គួយ ប៊ុនរឿន..........

**តំណាងគណបក្សប្រជាជនកម្ពុជា ៖**

ឯកឧត្តម ធុន តន..........

ឯកឧត្តម ស៊ិក ប៊ុនហុក..........

**តំណាងគណបក្សហ្វ៊ុនស៊ិនប៉ិច ៖**

ឯកឧត្តម យារ បូរ៉ា..........

**អ្នកសង្កេតការណ៍ជាតិ/អន្តរជាតិ**

.......... NICFEC

.......... (NIYA)

..........

..........

..........

..........

..........

..........

..........

..........

**ក្រុមលេខាកត់ត្រា គ.ជ.ប**

លោក កែវ ផល្លា..........

លោក កែ រឹទ្ធិ..........

លោក ព្រហ្ម វិចិត្រអក្ខរា..........

លោក ភាព វិរៈ..........

លោក ជោត វ៉ាន់ចាន់..........

លោក អ៊ូ សុផុន..........

**ក្រុមភ្នាក់ពិនិត្យផ្ទៀងផ្ទាត់**

លោក ហ៊ឹ វ៉ុង..........

លោក មុំ សុទ្ធ..........

លោក សាត់ សុវណ្ណ..........

លោក ហេង គុច..........

លោក អៀម សុង..........

លោក ម៉ែន សុខសុន្ទី..........

លោក នុត យូរៀម..........

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល
លេខ 226/030/2013
ថ្ងៃ 14. សីហា 2013
ម៉ោង 10:

**ពាក្យបណ្តឹងតវ៉ា**

ខ្ញុំបាទឈ្មោះ **កែវ គីរម្យ** អាយុ៥៥ឆ្នាំ ជាតំណាងគណបក្សសង្គ្រោះជាតិ មានទីលំនៅផ្ទះលេខ៤០ ផ្លូវលេខ៦A សង្កាត់ជ្រោយចង្វារ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**សូមគោរពចូលមក**
**ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**កម្មវត្ថុ:** ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលក្រចេះ។

**យោង:** - សម្រង់សេចក្តីសម្រេចលេខ០១៩/១៣ គ.ជ.ប.ស.ស.រ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។
- ពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣
- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម សម រង្ស៊ី។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជំរាបជូនឯកឧត្តមប្រធានមេត្តាជ្រាបថា កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ ខ្ញុំបាទ បានដាក់ពាក្យបណ្តឹងតវ៉ាទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទាមទារ:

១. ទាមទារឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បង្ហាញហេតុផលដែលប្រជាពលរដ្ឋបាត់ឈ្មោះពីបញ្ជីបោះឆ្នោតឆ្នាំ២០១២ នៅមណ្ឌលក្រចេះ។

២. ទាមទារឲ្យរាប់សន្លឹកឆ្នោតឡើងវិញ នៅការិយាល័យទាំង១៣ក្នុងឃុំស្វាយជ្រះ។

៣. ទាមទារឲ្យរាប់សន្លឹកឆ្នោតឡើងវិញ នៅការិយាល័យលេខ០០១១ឃុំដំរីផុង និងការិយាល័យលេខ ០០២៤ ឃុំកំពង់ដំរី។

៤. និងទាមទារឲ្យបោះឆ្នោតឡើងវិញនៅការិយាល័យលេខ០២៩២ឃុំវឌ្ឍនៈ។

ខ្ញុំបាទទាមទារយ៉ាងនេះដោយសំអាងថា:

១. នៅមណ្ឌលខេត្តក្រចេះទាំងមូល មានប្រជាពលរដ្ឋជាច្រើនបាត់ឈ្មោះពីបញ្ជីបោះឆ្នោតឆ្នាំ២០១២ ដោយមិនដឹងពីមូលហេតុច្បាស់លាស់។

២. នៅការិយាល័យទាំង១៣នៃឃុំស្វាយជ្រះ គឺការិយាល័យលេខ០២៥៩, ០២៦០, ០២៦១, ០២៦២, ០២៦៣, ០២៧៦, ០២៧៧, ០២៧៨, ០៣៥៥, ០៣៦៨, ០៣៧៩, ០៤០៧ និង០៤២៤ មានការក្លែងបន្លំតួលេខលើទំរង់១១០៤ គឺតួលេខដែលបង្ហាញនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៣ ខុសពីតួលេខលើទំរង់១១០៤ដែលគណបក្សសង្គ្រោះជាតិទទួលបាន។

៣. នៅការិយាល័យលេខ០០១១ ឃុំដំរីផុង មានសន្លឹកឆ្នោតមិនបានការច្រើនរហូតដល់៩៤សន្លឹក ហើយនៅការិយាល័យលេខ០០២៤ ឃុំដំពង់ដំរី មានសន្លឹកឆ្នោតមិនបានការរហូតដល់១១១សន្លឹក។

៤. នៅការិយាល័យលេខ០២៩២ ឃុំវឌ្ឍនៈ សន្លឹកឆ្នោតទាំងអស់ត្រូវបានបោះត្រាខុស គឺប្រធានការិយាល័យបានប្រគល់ត្រាការិយាល័យទៅបោះលើសន្លឹកឆ្នោត ខុសពីនីតិវិធីដែល គជប តម្រូវឲ្យប្រើ។

ក្រោយពីបានដាក់ពាក្យបណ្តឹងមក នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានចេញសេចក្តីសម្រេចបដិសេធពាក្យបណ្តឹងរបស់ខ្ញុំ។

ខ្ញុំបាទមិនសុខចិត្តនឹងការសម្រេចបដិសេធពាក្យបណ្តឹងរបស់ខ្ញុំចោលនេះទេ។

អាស្រ័យហេតុនេះ សូមឯកឧត្តមប្រធាន មេត្តាទទួលយកនូវពាក្យបណ្តឹងតវ៉ារបស់ខ្ញុំបាទ ដើម្បីដោះស្រាយតាមនីតិវិធី ដោយសេចក្តីអនុគ្រោះ។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣

**ហត្ថលេខា និងត្រា**



[illegible]

*<u>សូមជូនភ្ជាប់មកជាមួយនូវឯកសារថតចម្លង</u>*

- *សម្រង់សេចក្តីសម្រេចលេខ០១៩/១៣ ចំនួន០១ច្បាប់។*
- *ពាក្យបណ្តឹង ចំនួន០១ច្បាប់។*
- *លិខិតផ្ទេរសិទ្ធិ ចំនួន០១ច្បាប់។*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**អគ្គលេខាធិការដ្ឋាន**

លេខ ៖ ១១១/២០១៣ អ.កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣

**សូមគោរពជូន**

**ឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល**

**កម្មវត្ថុ** ៖ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ១៣១/០០៦/២០១៣ កបធ.ច ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ ។

**យោង** ៖ មាត្រា ៣៤ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន ឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល មេត្តាជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៣ វេលាម៉ោង ១៥ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យពាក្យបណ្តឹងចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **ជា ប៉ូច** តំណាងឱ្យឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តកំពត និងបានចេញជាសេចក្តីសម្រេច ដូចមានជូនភ្ជាប់មកជាមួយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាលមេត្តាជ្រាប និងចាត់ការបន្តតាមការគួរ។

សូមឯកឧត្តមអគ្គលេខាធិការ មេត្តាទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

**អគ្គលេខាធិការ**

**ចាន់ រ៉ាស៊ី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៣៣/០៣៧/២០១៣

ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣

**សេចក្តីសម្រេច**

លេខ : ១៣១/០០៦/២០១៣ កបធ.ច

ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៣

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១១/០១៣ ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១១ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញលិខិតលេខ ៨២៩/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញពាក្យបណ្តឹងចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **ជា ប៉ូច** ជាតំណាងគណបក្សសង្គ្រោះជាតិ ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តកំពត
- បានឃើញលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **សម រង្ស៊ី** ប្រធានគណបក្សសង្គ្រោះជាតិ ផ្ទេរសិទ្ធិជូនឯកឧត្តម **ជា ប៉ូច** ឱ្យធ្វើជាតំណាងគណបក្សសង្គ្រោះជាតិ ក្នុងការដាក់ពាក្យបណ្តឹងតវ៉ាទៅនឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្តកំពត
- បានឃើញលិខិតឧទ្ទេសនាមរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ៨៥៤/១៣ គ.ជ.ប ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ២០១៣
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ជា ប៉ូច** កាលពីថ្ងៃទី ២១ ខែ សីហា ឆ្នាំ២០១៣ ភ្ជាប់ដោយឯកសារភស្តុតាងចំនួនពីរជុំ
- បានឃើញកំណត់ហេតុឆ្លើយបំភ្លឺរបស់ឯកឧត្តម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ២២ ខែ សីហា ឆ្នាំ២០១៣ ភ្ជាប់ដោយសារណាការពារចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៣ ចំនួនបីទំព័រ ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា ពាក្យបណ្តឹងចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ របស់ឯកឧត្តម **ជា ប៉ូច** តំណាងគណបក្សសង្គ្រោះជាតិ បានដាក់នៅក្រុមប្រឹក្សាធម្មនុញ្ញ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ វេលាម៉ោង ១៥ និង ៣០ នាទី គឺស្ថិតក្នុងរយៈពេលដែលច្បាប់អនុញ្ញាតក្នុងចំណុចទី២ មាត្រា ២៧ ថ្មី នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ និង មាត្រា ១១៧ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ដូចនេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកបណ្តឹងខាងលើមកពិនិត្យបាន។

- យល់ឃើញថា ពាក្យបណ្តឹងរបស់ឯកឧត្តម **ជា ប៉ូច** ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ក៏ដូចជាការឆ្លើយបំភ្លឺ ចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ គឺទាមទារឱ្យបដិសេធលទ្ធផលនៃការបោះឆ្នោតនៅមណ្ឌលខេត្តកំពតទាំងមូល ទាមទារឱ្យរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតខេត្តកំពតឡើងវិញ និង ទាមទារឱ្យផ្ទៀងផ្ទាត់ឡើងវិញនូវទម្រង់ ១១០២ និង ទម្រង់ ១១០៤ ក្នុងកញ្ចប់ " ក " ទូទាំងខេត្តកំពត ។ ដើមបណ្តឹងបានសង្កត់ធ្ងន់លើចំណុចសំខាន់ពីរ គឺ ១-ការបាត់ឈ្មោះប្រជាពលរដ្ឋពីបញ្ជីបោះឆ្នោតឆ្នាំ២០១២ និង ២-ការមានអ្នកបោះឆ្នោតជំនួស
- យល់ឃើញថា នៅពេលឆ្លើយបំភ្លឺចំពោះមុខក្រុមទី២ នៃក្រុមប្រឹក្សាធម្មនុញ្ញ ឯកឧត្តម **ម៉ៅ សុភារិទ្ធ** តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ភ្ជាប់ដោយសារណាការពារចំនួនបីទំព័រ បានបញ្ជាក់ថា ការប្តឹងតវ៉ាពីការបាត់ឈ្មោះបោះឆ្នោតត្រូវធ្វើឡើងក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និង ចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ។ ការមានអ្នកមកបោះឆ្នោតជំនួស ឯកឧត្តម **ជា ប៉ូច** ពុំបានផ្តល់ភស្តុតាងជាក់លាក់ដែលអាចបញ្ជាក់ថា អ្នកមកបោះឆ្នោតជំនួសនោះទៅបោះឆ្នោតនៅការិយាល័យណាមួយដែលអាចឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពិនិត្យ និង វាយតម្លៃលើផលប៉ះពាល់បានឡើយ ។ ដើមបណ្តឹងមិនបានបញ្ជាក់ពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬ សមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះនិងអាសយដ្ឋាននៃសាក្សីព្រមទាំងឯកសារ ឬ ភស្តុតាងដទៃទៀត ដូចមានចែងក្នុងមាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ ។ តំណាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានធ្វើការប្រៀបធៀបពាក្យបណ្តឹងនៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង ពាក្យបណ្តឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ដើមបណ្តឹងបានបន្ថែមលើសមួយចំណុច គឺការទាមទារឱ្យផ្ទៀងផ្ទាត់ឡើងវិញនូវទម្រង់ ១១០២ និង ទម្រង់ ១១០៤ នៅក្នុងកញ្ចប់សុវត្ថិភាព " ក " ទូទាំងខេត្តកំពត
- យល់ឃើញថា ការប្តឹងតវ៉ាពីការបាត់ឈ្មោះត្រូវធ្វើឡើងក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និង ការចុះឈ្មោះបោះឆ្នោត គឺចាប់ពីថ្ងៃទី ០១ ខែ តុលា រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ជារៀងរាល់ឆ្នាំ ។ នៅឆ្នាំដែលមានការបោះឆ្នោតសកល ដូចជាឆ្នាំ២០១៣ នេះ ការពិនិត្យបញ្ជីឈ្មោះ និង ការចុះឈ្មោះបោះឆ្នោតបានចាប់ធ្វើពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១២ គឺធ្វើមុនមួយខែ ដែលមានចែងក្នុងប្រតិទិនរបស់គណៈ-កម្មាធិការជាតិរៀបចំបោះឆ្នោត ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១២ ស្របតាមបទប្បញ្ញត្តិនៃមាត្រា ៤៩ ថ្មី ( បី ) នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និង ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ។ បណ្តឹងតវ៉ា ឬ ជំទាស់នឹងការបាត់ឈ្មោះ លុបឈ្មោះ និង ការចុះឈ្មោះបោះឆ្នោត បានផុតអាជ្ញាយុកាលហើយ ។ តាមច្បាប់ បញ្ជីបោះឆ្នោតដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានផ្តល់សុពលភាពពីថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១២ គឺជាបញ្ជីបោះឆ្នោតផ្លូវការត្រូវយកមកប្រើនៅពេលបោះឆ្នោត កាលពីថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ២០១៣ ។

-យល់ឃើញថា ការមានប្រជាពលរដ្ឋជាច្រើនត្រូវគេបោះឆ្នោតជំនួសនៅថ្ងៃបោះឆ្នោត ដើមបណ្តឹងពុំបានបង្ហាញភស្តុតាងច្បាស់លាស់ ដែលបញ្ជាក់ថា អ្នកបោះឆ្នោតជំនួសនោះនៅការិយាល័យលេខប៉ុន្មាន ចំនួនប៉ុន្មាននាក់ និង ឈ្មោះណាខ្លះឡើយ

- យល់ឃើញថា ដើមបណ្តឹងមិនបានបញ្ជាក់ពីភាពមិនប្រក្រតីរបស់គណៈកម្មការ ឬ សមាជិកគណៈកម្មការដែលធ្វើខុស ពីកាលបរិច្ឆេទដែលធ្វើខុស ពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះនិងអាសយដ្ឋាននៃសាក្សីព្រមទាំងឯកសារ ឬ ភស្តុតាងដទៃទៀត ដូចមានចែងក្នុងបទប្បញ្ញត្តិនៃមាត្រា ១១៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រទេ

- យល់ឃើញថា នៅមណ្ឌលខេត្តកំពតសរុបមាន ៨៤៨ ការិយាល័យ ការបោះឆ្នោតពុំមានអំពើហិង្សា និងពុំមានចលាចលវឹកវរទេ ។ ប្រជាពលរដ្ឋបានទៅបោះឆ្នោតដោយសម្ងាត់ និង ដោយសេរី ដែលមានអត្រា ៦៨,៩៦%

- យល់ឃើញថា លិខិតលេខ ៨២៩/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

## សម្រេច

**មាត្រា ១.-** ទទួលពាក្យបណ្តឹងរបស់ឯកឧត្តម **ជា ប៉ូច** ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ២០១៣ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

**មាត្រា ២.-** តម្កល់លិខិតលេខ ៨២៩/១៣ គ.ជ.ប ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ២០១៣ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ២០១៣

ជ. ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

ឯក សំអុល

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

323

ក្រុមប្រឹក្សាធម្មនុញ្ញ
ចូល
លេខ 323/037/...
ថ្ងៃ 14 សីហា 2013
បញ្ជូន 15ម៉ោង30នាទី

## ពាក្យបណ្តឹងតវ៉ា

ខ្ញុំបាទឈ្មោះ **ខា ម៉ុច** ឆ្នាំកំណើត ១៩៧៤ ជាតំណាងគណបក្សសង្គ្រោះជាតិ មានទីលំនៅផ្ទះលេខ៦២០ ផ្លូវលេខ៦A សង្កាត់ ព្រែកលាប ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**សូមគោរពចូលមក**
**ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**កម្មវត្ថុ:** ប្តឹងតវ៉ានឹងលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៥ ឆ្នាំ២០១៣ នៅមណ្ឌលខេត្ត កំពត ។

**យោង:** - លិខិតលេខ៨២៩/១៣ គ.ជ.ប ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់គណៈ កម្មាធិការជាតិរៀបចំការបោះឆ្នោត។
- ពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣
- លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ របស់ឯកឧត្តម សម រង្ស៊ី។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជំរាបជូនឯកឧត្តមប្រធានមេត្តាជ្រាបថា កាលពីថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៣ ខ្ញុំបាទ បានដាក់ពាក្យបណ្តឹងតវ៉ាទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទាមទារ:

១. តវ៉ាឲ្យបដិសេធលទ្ធផលនៃការបោះឆ្នោតនៅមណ្ឌលខេត្ត កំពតទាំងមូល។

២. ទាមទារឲ្យរៀបចំបញ្ជីឈ្មោះអ្នកបោះឆ្នោតខេត្ត កំពតឡើងវិញ។

៣. ទាមទារឲ្យផ្ទៀងផ្ទាត់ឡើងវិញនូវទំរង់១១០២និងទំរង់១១០៤ក្នុងកញ្ចប់(ក)នូទាំងខេត្ត កំពត។

ខ្ញុំបាទទាមទារយ៉ាងនេះដោយសំអាងថា:

១. នៅមណ្ឌលខេត្ត កំពត ទាំងមូល មានប្រជាពលរដ្ឋជាច្រើនបាត់ឈ្មោះពីបញ្ជីបោះឆ្នោតឆ្នាំ២០១២ ដោយមិនដឹងពីមូលហេតុច្បាស់លាស់និង ប្រជាពលរដ្ឋជាច្រើនត្រូវគេបោះជំនួសនៅថ្ងៃបោះឆ្នោត។

២.នៅស្ទើតែគ្រប់ការិយាល័យទូទាំងខេត្ត កំពតមានការក្លែងបន្លំតួលេខលើទំរង់១១០៤ គឺតួលេខដែលបង្ហាញនៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៣ ខុសពីតួលេខលើទំរង់១១០៤ដែលគណបក្ស សង្គ្រោះជាតិទទួលបាន។

ក្រោយពីបានដាក់ពាក្យបណ្តឹងមក នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានសម្រេចបដិសេធពាក្យបណ្តឹងរបស់ខ្ញុំ។

ខ្ញុំបាទមិនសុខចិត្តនឹងការសម្រេចបដិសេធពាក្យបណ្តឹងរបស់ខ្ញុំចោលនេះទេ។

អាស្រ័យហេតុនេះ សូមឯកឧត្តមប្រធាន មេត្តាទទួលយកនូវពាក្យបណ្តឹងតវ៉ារបស់ខ្ញុំបាទ ដើម្បីដោះស្រាយតាមនីតិវិធី ដោយសេចក្តីអនុគ្រោះ។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៣

**ហត្ថលេខា**

*សូមជូនភ្ជាប់មកជាមួយនូវឯកសារថតចម្លង*

- *លិខិតលេខ៨២១/១៣* *ចំនួន០១ច្បាប់។*
- *ពាក្យបណ្តឹង* *ចំនួន០១ច្បាប់។*
- *លិខិតផ្ទេរសិទ្ធិ* *ចំនួន០១ច្បាប់។*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

៙៙៙*៙៙៙

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៤៧៥ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/ នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញប្រកាសលេខ ១០១៨ សហវ.ប្រក,ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិ ផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១**:-

ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកា ចំនួន ៤៨១.០០០.០០០ រៀល (បួនរយប៉ែតសិបមួយលានរៀលគត់) ពីជំពូក ៦០ (ការទិញ) មកជំពូក៦១ (សេវាខាងក្រៅ) ជូនក្រសួងផែនការ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ។

**មាត្រា២**:-

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់បំពេញតម្រូវការចំណាយបម្រើនិរន្តរភាពការងារកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រឆ្នាំ២០១៣ (ថតរូបគ្រួសារក្រីក្រ) ។

**មាត្រា៣**:-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ ជាអ្នកទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា
**រដ្ឋមន្ត្រីស្តីទី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អ៊ុក រ៉ាប៊ុន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤៧៦.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## បរធនបាលកិច្ចហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីវិធាន និងនីតិវិធី នៃការបង្កើត ការចុះបញ្ជី ការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលបំណងគ្រប់គ្រងមូលនិធិជាបរធនដែលរាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះបរធនបាលកិច្ចហិរញ្ញវត្ថុដែលទទួលមូលនិធិហិរញ្ញប្បទាន ឬហិរញ្ញប្បទានឥតសំណងរបស់ដៃគូអភិវឌ្ឍ ឬអនុបំណុល ក្នុងគោលបំណងអភិវឌ្ឍវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤.-**

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសមត្ថកិច្ចជាបញ្ញត្តិករ នៃបរធនបាលកិច្ចហិរញ្ញវត្ថុដែលមានភារកិច្ចជាអាទិ៍ដូចខាងក្រោម÷

- កំណត់វិធាន និងនីតិវិធីនៃការបង្កើត ការចុះបញ្ជី ការគ្រប់គ្រង និងការត្រួតពិនិត្យរបស់បរធនបាលកិច្ចហិរញ្ញវត្ថុ
- កំណត់ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុសម្រាប់បរធនបាលកិច្ចហិរញ្ញវត្ថុ
- ចុះបញ្ជី និងគ្រប់គ្រងបញ្ជីរបស់បរធនបាលកិច្ចហិរញ្ញវត្ថុ
- កត់ត្រាក្នុងបញ្ជីនូវរាល់ការផ្លាស់ប្តូរពាក់ព័ន្ធនឹងបរធនបាលកិច្ចហិរញ្ញវត្ថុ
- គ្រប់គ្រង និងត្រួតពិនិត្យដំណើរការរបស់បរធនបាលកិច្ចហិរញ្ញវត្ថុ
- កំណត់ទណ្ឌកម្មវិន័យ និងវិធានការរដ្ឋបាលចំពោះសកម្មភាពបំពានបទប្បញ្ញត្តិពាក់ព័ន្ធបរធនបាលកិច្ចហិរញ្ញវត្ថុ
- ចាត់វិធានការតាមផ្លូវច្បាប់ ដើម្បីដកហូតបរធនឱ្យរដ្ឋគ្រប់គ្រងជំនួស ឬចាត់តាំងបរធនបាលជំនួស ក្នុងករណីបរធនបាលមិនអនុវត្តតាមខ្លឹមសារនៃលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ និងបទប្បញ្ញត្តិជាធរមាន
- ប្រកាសបញ្ចប់បរធនបាលកិច្ចហិរញ្ញវត្ថុ តាមសំណើរបស់បរធនបាលទាយក បន្ទាប់ពីការជម្រះបញ្ជី
- ចាត់វិធានការតាមផ្លូវច្បាប់ ចំពោះបុគ្គលដែលគ្រប់គ្រងមូលនិធិជាបរធនដែលមិនបានចុះបញ្ជី

- ផ្សះផ្សា និងធ្វើសេចក្តីសម្រេចលើវិវាទដែលពាក់ព័ន្ធនឹងបរធនបាលកិច្ចហិរញ្ញវត្ថុ នៅក្នុងក្របខណ្ឌនៃក្រុមប្រឹក្សានីតិកម្ម
- បង្កើតមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យបរធនបាលកិច្ចហិរញ្ញវត្ថុ
- បំពេញកិច្ចការផ្សេងទៀតដែលចាំបាច់សម្រាប់ការទ្រទ្រង់ និងអភិវឌ្ឍវិស័យបរធនបាលកិច្ចហិរញ្ញវត្ថុ។

**មាត្រា៥ .-**

ពាក្យបច្ចេកទេសដែលប្រើប្រាស់នៅក្នុងអនុក្រឹត្យនេះមានន័យ ដូចខាងក្រោម÷

**-បរធន** សំដៅដល់ទ្រព្យសម្បត្តិ ឬមូលនិធិដែលបានមកពីមូលនិធិហិរញ្ញប្បទាន ឬហិរញ្ញប្បទានឥតសំណងរបស់ដៃគូអភិវឌ្ឍ ដែលបានចុះកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាល និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់គ្រឹះស្ថានធនាគារ និងមីក្រូហិរញ្ញវត្ថុ។

**-បរធនបាល** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលថែរក្សា និងគ្រប់គ្រងបរធន ដោយអនុលោមតាមបរធនបាលកិច្ចហិរញ្ញវត្ថុ ដែលត្រូវបានចុះបញ្ជី នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**-បរធនបាលទាយក** សំដៅដល់ដៃគូអភិវឌ្ឍដែលបានចុះកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលក្នុងគោលបំណងផ្តល់មូលនិធិជាបរធនឱ្យទៅបរធនបាល សម្រាប់អភិវឌ្ឍវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ ដើម្បីជាប្រយោជន៍ដល់អត្ថគាហកៈនៅព្រះរាជាណាចក្រកម្ពុជា។

**-អត្ថគាហកៈ** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលទទួលប្រយោជន៍អំពីបរធនបាលកិច្ចហិរញ្ញវត្ថុ។

**-បរធនបាលកិច្ច** សំដៅដល់កិច្ចការរបស់បរធនបាលក្នុងការថែរក្សា និងគ្រប់គ្រងបរធនដែលផ្តល់ដោយបរធនបាលទាយក ដើម្បីជាប្រយោជន៍ដល់អត្ថគាហកៈ ដោយអនុលោមតាមលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ។

**-លិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ** សំដៅដល់លិខិតគតិយុត្ត ដែលកំណត់អំពីការបង្កើត ការគ្រប់គ្រង ការត្រួតពិនិត្យ និងការបញ្ចប់បរធនបាលកិច្ចហិរញ្ញវត្ថុ។

**-មូលនិធិហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ** សំដៅដល់សមតុល្យហិរញ្ញប្បទានឥតសំណងសរុបចុងក្រោយ បន្ទាប់ពីត្រូវបានប្រើប្រាស់ស្របតាមគោលបំណងរបស់បរធនបាលកិច្ចហិរញ្ញវត្ថុ។ សមតុល្យនេះត្រូវគណនាតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា សម្រាប់គោលបំណងនៃការចុះបញ្ជី។

**-ហិរញ្ញប្បទានឥតសំណងរបស់ដៃគូអភិវឌ្ឍ** សំដៅដល់មូលនិធិជំនួយឥតសំណងដំបូងដែលត្រូវបានផ្តល់ដោយដៃគូអភិវឌ្ឍឱ្យទៅបុគ្គលណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់គោលបំណងនៃបរធនបាលកិច្ចហិរញ្ញវត្ថុ។

**-អនុបំណុល** សំដៅដល់មូលនិធិហិរញ្ញប្បទាន ឬហិរញ្ញប្បទានឥតសំណងរបស់ដៃគូអភិវឌ្ឍ ដែលកំពុងត្រូវបានប្រើប្រាស់ដោយនីតិបុគ្គលណាមួយ ក្នុងគោលបំណងបន្តសកម្មភាពអភិវឌ្ឍន៍វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុក្រោមកិច្ចព្រមព្រៀងអនុបំណុល។

**-កិច្ចព្រមព្រៀងអនុបំណុល** សំដៅដល់កិច្ចព្រមព្រៀងដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើឡើងជាមួយដៃគូអភិវឌ្ឍ ដើម្បីទទួលយកអនុបំណុលមកគ្រប់គ្រងជំនួស សម្រាប់បន្តសកម្មភាពអភិវឌ្ឍន៍វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ។

-**ឆ្នាំសារពើពន្ធ** សំដៅរយៈពេលរាប់គិតចាប់ពីថ្ងៃទី ០១ ខែ មករា ឬថ្ងៃផ្តើមធ្វើប្រតិបត្តិការ ចំពោះបរធនបាលកិច្ចហិរញ្ញវត្ថុទើបបង្កើតថ្មី រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឬរយៈពេលផ្សេងទៀតដែលសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី ២
## ការបង្កើត និងការគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុ

**មាត្រា៦ ..**

បរធនបាលកិច្ចហិរញ្ញវត្ថុ ត្រូវបង្កើតឡើងដោយលិខិតលាយលក្ខណ៍អក្សរតាមទម្រង់កំណត់ និងត្រូវចុះបញ្ជីនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បុគ្គលទាំងឡាយណាដែលមានបំណងបង្កើត ឬធ្វើប្រតិបត្តិការបរធនបាលកិច្ចហិរញ្ញវត្ថុ មានកាតព្វកិច្ចរៀបចំបង្កើតលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ និងចុះបញ្ជីនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមុនសិន តាមវិធាន និងនីតិវិធីជាធរមាន។

បុគ្គលទាំងឡាយណាដែលទទួលមូលនិធិជាបរធន ដែលរាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍ និងដៃគូអភិវឌ្ឍពាក់ព័ន្ធ មានកាតព្វកិច្ចបង្កើតបរធនបាលកិច្ចហិរញ្ញវត្ថុ និងចុះបញ្ជីនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមវិធាន និងនីតិវិធីជាធរមាន។ ក្នុងករណីដែលដៃគូអភិវឌ្ឍពាក់ព័ន្ធពុំមានលទ្ធភាព ឬសមត្ថភាពជាស្ថាពរក្នុងការចូលរួមបង្កើតបរធនបាលកិច្ចហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសមត្ថកិច្ចបំពេញមុខងារជំនួស។

បទប្បញ្ញត្តិខាងលើនេះត្រូវយកមកអនុវត្តផងដែរ ចំពោះបុគ្គលទាំងឡាយដែលគ្រប់គ្រងអនុបំណុល។

**មាត្រា៧ ..**

បរធនបាលកិច្ចហិរញ្ញវត្ថុ មានសុពលភាព និងអានុភាពគតិយុត្ត លុះត្រាតែត្រូវបានចុះបញ្ជី នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រេចទទួលចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ ក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីទទួលបានសំណើដែលបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ សម្រាប់ការចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ។

ក្នុងករណីបដិសេធ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបញ្ជាក់អំពីមូលហេតុច្បាស់លាស់តាមរយៈលិខិតលាយលក្ខណ៍អក្សរផ្ញើជូនទៅម្ចាស់សំណើ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីទទួលបានសំណើ។

**មាត្រា៨ ..**

បរធនបាលកិច្ចហិរញ្ញវត្ថុដែលមានសុពលភាព ត្រូវមានអានុភាពបង្កើតសិទ្ធិ និងកាតព្វកិច្ចដល់បរធនបាលទាយក បរធនបាល និងអត្ថគាហកៈ តាមលក្ខខណ្ឌ និងខ្លឹមសារដែលមានចែងក្នុងលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ និងបទប្បញ្ញត្តិជាធរមាន។

រាល់ប្រតិបត្តិការបរធនបាលកិច្ចហិរញ្ញវត្ថុ ត្រូវស្ថិតនៅក្រោមច្បាប់ និងបទប្បញ្ញត្តិស្តីពីសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី ៣
## បរធនបាលទាយក និង អត្ថគាហកៈ

**មាត្រា៩ .-**

បរធនបាលទាយកមានសិទ្ធិជាសារវន្ត ដូចខាងក្រោម÷

- ទទួលព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុ ដែលមានជាអាទិ៍របាយការណ៍ហិរញ្ញវត្ថុ របាយការណ៍សវនកម្ម និងឯកសារពាក់ព័ន្ធផ្សេងទៀត
- តែងតាំង និងបញ្ឈប់បរធនបាល តាមលក្ខខណ្ឌដែលបានកំណត់
- អាចបំពេញមុខងារជាបរធនបាលដោយខ្លួនឯង
- បញ្ចប់បរធនបាលកិច្ចហិរញ្ញវត្ថុ ក្នុងករណីដែលគោលបំណងនៃបរធនបាលកិច្ចហិរញ្ញវត្ថុមិនត្រូវបានបំពេញត្រឹមត្រូវ ឬត្រូវបានសម្រេចរួចរាល់ហើយ
- បញ្ចប់បរធនបាលកិច្ចហិរញ្ញវត្ថុ ដោយឆន្ទានុសិទ្ធិ ឬមតិជាឯកច្ឆន្ទក្នុងករណីបរធនបាលទាយកមានច្រើនស្របតាមវិធាន និងនីតិវិធីជាធរមាន
- ចាត់តាំងអភិបាលបណ្តោះអាសន្នសម្រាប់គ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុ ក្នុងករណីយល់ឃើញថាមានហានិភ័យលើសាធនភាព
- ចាត់តាំងអ្នកជម្រះបញ្ជី ក្នុងករណីបរធនបាលកិច្ចហិរញ្ញវត្ថុត្រូវបានបញ្ចប់។

**មាត្រា១០ .-**

បរធនបាលទាយកមានកាតព្វកិច្ចជាសារវន្ត ដូចតទៅ÷

- ផ្ទេរទ្រព្យសម្បត្តិ ឬមូលនិធិជាបរធនឱ្យទៅបរធនបាលថែរក្សា និងគ្រប់គ្រងជំនួស ដើម្បីជាប្រយោជន៍ដល់អត្ថគាហកៈ
- ចូលរួម ឬសម្រួលក្នុងកិច្ចការផ្ទេរបរធនជូនទៅបរធនបាលថែរក្សា និងគ្រប់គ្រង
- គោរពតាមខ្លឹមសារ និងលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា១១ .-**

រាល់ការផ្លាស់ប្តូរបរធនបាលទាយក ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយសាមីបរធនបាលទាយក។

ការផ្លាស់ប្តូរនេះត្រូវកត់ត្រាក្នុងបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ។

**មាត្រា១២ ._**

ក្នុងករណីដែលបរធនបាលទាយកពុំមានលទ្ធភាព ឬសមត្ថភាពជាស្ថាពរក្នុងការអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសមត្ថកិច្ចបំពេញមុខងារជាបរធនបាលទាយកជំនួស។

**មាត្រា១៣ ._**

អត្ថគាហកៈ មានសិទ្ធិជាសារវន្ត ដូចខាងក្រោម៖

- ទទួលអត្ថប្រយោជន៍ពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- ទាមទារឱ្យបរធនបាលបំពេញកាតព្វកិច្ច ដែលកំណត់ដោយលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ និងបទប្បញ្ញត្តិជាធរមាន
- ទទួលព័ត៌មានពាក់ព័ន្ធនឹងដំណើរការនៃបរធនបាលកិច្ចហិរញ្ញវត្ថុ
- ប្តឹងទាមទារឱ្យបរធនបាល គោរពកាតព្វកិច្ចនៃបរធនបាលកិច្ចហិរញ្ញវត្ថុ។

## ជំពូកទី ៤

## បរធនបាល

**មាត្រា១៤ ._**

បរធនបាលត្រូវមានសមាសភាពជាក្រុមនៃរូបវន្តបុគ្គល ក្រុមនៃនីតិបុគ្គល ក្រុមចម្រុះរវាងរូបវន្តបុគ្គល និងនីតិបុគ្គល ឬជានីតិបុគ្គលតែមួយ។

ក្នុងករណីជាក្រុម បរធនបាលត្រូវមានសមាសភាពចំនួន ០៣ (បី) រូប ឬ ០៥ (ប្រាំ) រូប ដែលជារូបវន្តបុគ្គល ឬតំណាងនីតិបុគ្គល។ នីតិបុគ្គលនីមួយៗមានសិទ្ធិចាត់តាំងតំណាងតែ ០១ (មួយ) រូបប៉ុណ្ណោះ ចូលរួមក្នុងសមាសភាពបរធនបាល។ សេចក្តីសម្រេចក្នុងកិច្ចការគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុត្រូវធ្វើឡើងតាមសម្លេងភាគច្រើន។

ក្នុងករណីបរធនបាលជានីតិបុគ្គលតែមួយ បរធនបាលកិច្ចហិរញ្ញវត្ថុត្រូវគ្រប់គ្រងដោយថ្នាក់ដឹកនាំនៃនីតិបុគ្គលនោះ។

**មាត្រា១៥ ._**

រាល់ការផ្លាស់ប្តូរបរធនបាល ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយបរធនបាលទាយក។

ការផ្លាស់ប្តូរនេះត្រូវកត់ត្រាក្នុងបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ។

**មាត្រា១៦ ._**

បរធនបាលមានសិទ្ធិ ដូចខាងក្រោម៖

- ទទួលលាភការ ឬកម្រៃនានា ក្នុងក្របខណ្ឌនៃការគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុ
- គ្រប់គ្រង និងប្រើប្រាស់បរធន ក្នុងគោលបំណងនៃបរធនបាលកិច្ចហិរញ្ញវត្ថុ
- ស្វែងរកទីប្រឹក្សា ឬជំនួយការបច្ចេកទេស សម្រាប់ពង្រឹង និងពង្រីកការងារបរធនបាលកិច្ចហិរញ្ញវត្ថុ
- អភិវឌ្ឍបរធនបាលកិច្ចហិរញ្ញវត្ថុ តាមរយៈការវិនិយោគមូលនិធិបរធន ក្រោមរូបភាពជាឥណទាន ឬដើមទុន
- ចំណាយក្នុងសកម្មភាពសង្គម ស្របតាមគោលបំណងបរធនបាលកិច្ចហិរញ្ញវត្ថុ
- អនុវត្តចំណាយ និងទូទាត់ចំណូលដែលបានមកពីការគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុ។ ក្នុងករណីចំណូលមានចំនួនមិនគ្រប់គ្រាន់សម្រាប់ទូទាត់ចំណាយ ចំនួននៃចំណាយដែលខ្វះ អាចទូទាត់ចេញពីបរធនបាន លុះត្រាតែបរធនបាលមានការបញ្ជាក់អំពីមូលហេតុច្បាស់លាស់។

**មាត្រា១៧ .-**

បរធនបាលមានកាតព្វកិច្ច ដូចខាងក្រោម÷

- បំពេញមុខងារ នៅក្នុងបរធនបាលកិច្ចហិរញ្ញវត្ថុ ដោយខ្លួនឯងផ្ទាល់ ប្រកបដោយការយកចិត្តទុកដាក់ និងការប្រុងប្រយ័ត្ន ប្រៀបដូចជាបំពេញការងាររបស់ខ្លួន
- ពុំអាចផ្ទេរមុខងាររបស់ខ្លួនទៅឱ្យបុគ្គលដទៃឡើយ
- ប្រកាន់ជំហរអព្យាក្រឹត នៅចំពោះបណ្តាអត្ថគាហកៈ
- ត្រូវបែងចែកឱ្យបានច្បាស់លាស់រវាងទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងបរធន ដោយមិនត្រូវទាញយកផលប្រយោជន៍ខុសច្បាប់ ពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- ត្រូវចុះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិ នៃបរធនបាលកិច្ចហិរញ្ញវត្ថុ
- រក្សាភាពស្មោះត្រង់ និងសុចរិតភាព នៅក្នុងការបំពេញមុខងាររបស់ខ្លួន
- ចាត់វិធានការសមស្រប ចំពោះកិច្ចការពារអំពើរំលោភលើទំនុកចិត្ត
- ផ្តល់របាយការណ៍ និងព័ត៌មានពាក់ព័ន្ធបរធនបាលកិច្ចហិរញ្ញវត្ថុទៅឱ្យបរធនបាលទាយក អត្ថគាហកៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ផ្តល់ផលប្រយោជន៍តាមការកំណត់ទៅឱ្យអត្ថគាហកៈ
- ចុះកិច្ចសន្យាធានារ៉ាប់រងលើភារៈទទួលខុសត្រូវលើមុខងារជាបរធនបាល
- គោរពតាមខ្លឹមសារ និងលក្ខខណ្ឌដែលកំណត់ដោយលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៨ .-**

បរធនបាល មានកាតព្វកិច្ចទទួលខុសត្រូវ ចំពោះសកម្មភាព ដូចខាងក្រោម÷

- ការបាត់បង់ ឬការថយចុះនៃបរធន ដោយគ្មានមូលហេតុត្រឹមត្រូវ
- ការខកខានមិនបានបង្គរប្រាក់ចំណេញទុកនៅក្នុងបរធន
- ការប្រើប្រាស់បរធន ដោយខុសពីគោលបំណងនៃបរធនបាលកិច្ចហិរញ្ញវត្ថុ
- កំហុសដែលបានប្រព្រឹត្តដោយចេតនា ឬការធ្វេសប្រហែសក្នុងការអនុវត្តមុខងាររបស់ខ្លួន

- រាល់ការចំណាយ ដែលខុសគោលដៅនៃបរធនបាលកិច្ចហិរញ្ញវត្ថុ។

**មាត្រា១៩ .-**

បរធនបាលត្រូវមានក្រមសីលធម៌វិជ្ជាជីវៈជាសារវន្ត ដូចខាងក្រោម÷

- បំពេញភារកិច្ចដោយភាពស្មោះត្រង់
- ជំរុញឱ្យមានជោគជ័យនៃបរធនបាលកិច្ចហិរញ្ញវត្ថុ ដើម្បីជាប្រយោជន៍ដល់អត្ថគាហកៈទាំងឡាយ ដោយរួមបញ្ចូលទាំងពង្រឹងប្រសិទ្ធភាពក្នុងការទាមទារសំណងជូនបរធនបាលកិច្ចហិរញ្ញវត្ថុ និងការពារការទាមទារសំណងពីបរធនបាលកិច្ចហិរញ្ញវត្ថុ
- ធ្វើការសម្រេចចិត្តដោយឯករាជ្យ ដោយមានការវិនិច្ឆ័យស្របតាមចំណេះដឹង ជំនាញ និងបទពិសោធន៍វិជ្ជាជីវៈ
- ជៀសវាងស្ថានភាពដែលបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ទោះដោយផ្ទាល់ ឬដោយប្រយោល ហើយធ្វើឱ្យប៉ះពាល់ដល់ប្រយោជន៍របស់បរធនបាលកិច្ចហិរញ្ញវត្ថុ
- មិនអាចទទួលយកផលប្រយោជន៍ពីតតិយជនបានឡើយ ក្នុងករណីមានទំនាស់ផលប្រយោជន៍។

**មាត្រា២០ .-**

លាភការរបស់បរធនបាល ត្រូវកំណត់ក្នុងលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ ដោយផ្អែកលើគុណវុឌ្ឍិវិជ្ជាជីវៈ និងបទពិសោធន៍ការងារ។

## ជំពូកទី ៥
## ការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ

**មាត្រា២១ .-**

បរធនបាលត្រូវបំពេញកាតព្វកិច្ចរបាយការណ៍ ដូចខាងក្រោម÷

-អនុម័តរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំនៅក្នុងកិច្ចប្រជុំបរធនបាលតាមសម្លេងភាគច្រើន ដោយមានហត្ថលេខាបញ្ជាក់ពីបរធនបាលគ្រប់រូប និងផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងរយៈពេល ០៣ (បី) ខែ បន្ទាប់ពីដំណាច់ឆ្នាំសារពើពន្ធ

-ស្នើសុំពន្យារពេលពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនកាលវសាននៃថ្ងៃផ្ដល់របាយការណ៍ហិរញ្ញវត្ថុ ក្នុងករណីមានការយឺតយ៉ាវ

-បំពេញបន្ថែមព័ត៌មានលើរបាយការណ៍ហិរញ្ញវត្ថុ តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា២២ .-**

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំត្រូវធ្វើសវនកម្មដោយសវនករឯករាជ្យ។

ការជ្រើសរើសសវនករឯករាជ្យ ត្រូវសម្រេចនៅដើមឆ្នាំសារពើពន្ធនីមួយៗ ដោយបរធនបាល តាមការអនុម័តដោយសម្លេងភាគច្រើន។

## ជំពូកទី ៦

## ការបញ្ចប់បរធនបាលកិច្ចហិរញ្ញវត្ថុ

**មាត្រា២៣ .-**

បរធនបាលកិច្ចហិរញ្ញវត្ថុអាចត្រូវបានបញ្ចប់ក្នុងករណី ដូចខាងក្រោម÷

- ការសម្រេចដោយឆន្ទានុសិទ្ធិ ឬមតិជាឯកច្ឆន្ទរបស់បរធនបាលទាយក
- ការមកដល់នៃកាលវសាន ដែលកំណត់នៅក្នុងលិខិតបរធនបាលកិច្ចហិរញ្ញវត្ថុ
- ការបំពានធ្ងន់ធ្ងររបស់បរធនបាលលើបរធនបាលកិច្ចហិរញ្ញវត្ថុ។

**មាត្រា២៤ .-**

ក្នុងករណីដែលបរធនបាលកិច្ចហិរញ្ញវត្ថុ ត្រូវបានបញ្ចប់ដូចមានចែងក្នុងមាត្រា២៣ ខាងលើ បរធនបាលទាយកត្រូវជ្រើសតាំងអ្នកជម្រះបញ្ជី ដើម្បីគ្រប់គ្រងនិងវាយតម្លៃបរធន។

បរធនបាលកិច្ចហិរញ្ញវត្ថុ ត្រូវបន្តអត្ថិភាពគតិយុត្ត រហូតដល់ការជម្រះបញ្ជីត្រូវបានបញ្ចប់ជាស្ថាពរ។

**មាត្រា២៥ .-**

អ្នកជម្រះបញ្ជីមានភារកិច្ច ដូចខាងក្រោម÷

- បំពេញ និងបញ្ចប់កិច្ចការដែលនៅសេសសល់របស់បរធនបាល
- ប្រមូល និងទូទាត់បំណុលដែលនៅសល់
- វាយតម្លៃបរធនដែលនៅសល់។

បរធនដែលនៅសល់ក្រោយពីការជម្រះបញ្ជី ត្រូវប្រគល់ជូនបរធនបាលទាយក ឬទុកជាទ្រព្យសម្បត្តិរដ្ឋ។

**មាត្រា២៦ .-**

តម្លៃការ និងសោហ៊ុយដែលកើតចេញពីការអភិបាលបណ្តោះអាសន្ន ឬជម្រះបញ្ជីត្រូវគិតគូរលើមូលដ្ឋាននៃអត្រាតម្លៃវិជ្ជាជីវៈ និងជាបន្ទុកស្វ័យប្រវត្តិរបស់បរធនបាលកិច្ចហិរញ្ញវត្ថុ។

## ជំពូកទី ៧

## ការដោះស្រាយវិវាទ

**មាត្រា២៧ .-**

វិវាទពាក់ព័ន្ធនឹងប្រតិបត្តិការនៃបរធនបាលកិច្ចហិរញ្ញវត្ថុ ត្រូវដោះស្រាយក្នុងក្របខណ្ឌនៃក្រុមប្រឹក្សានីតិកម្មនៃ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយការផ្សះផ្សា សម្រុះសម្រួល ឬការធ្វើសេចក្តីសម្រេច។

ចំពោះវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការនៃបរធនបាលកិច្ចហិរញ្ញវត្ថុមិនទាន់បានចុះបញ្ជី ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានសិទ្ធិអំណាចចាត់វិធានការដោះស្រាយតាមផ្លូវច្បាប់ ដើម្បីដកហូតបរធនឱ្យរដ្ឋគ្រប់គ្រងជំនួស។

**មាត្រា២៨ .-**

ភាគី ដែលមិនយល់ព្រមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានសិទ្ធិប្តឹងចំពោះសេចក្តីសម្រេចនេះ ក្នុងរយៈពេល ១ (មួយ) ខែ ទៅមជ្ឈត្តការ ឬតុលាការមានសមត្ថកិច្ច នៃព្រះរាជាណាចក្រកម្ពុជា។

ដើម្បីការពារសេចក្តីសម្រេចលើវិវាទដែលកើតចេញពីបរធនបាលកិច្ចហិរញ្ញវត្ថុ នៅចំពោះមុខស្ថាប័នតុលាការ ក្រុមប្រឹក្សានីតិកម្មត្រូវចាត់តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានសមាសភាពជាមន្ត្រីជំនាញបរធនបាលកិច្ចហិរញ្ញវត្ថុ និងមន្ត្រីច្បាប់របស់ក្រសួង តាមសំណើរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សានីតិកម្ម។

## ជំពូកទី ៨

## ទោសប្បញ្ញត្តិ

**មាត្រា២៩ .-**

បរធនបាល ដែលគ្រប់គ្រង ឬប្រើប្រាស់បរធន ក្នុងលក្ខណៈមិនសមស្រប ឬខុសគោលបំណងនៃបរធនបាលកិច្ចហិរញ្ញវត្ថុ ឬធ្វើឱ្យបាត់បង់ តាមរយៈការលួចកិបកេង ការក្លែងបន្លំនានា ការក្លែងបន្លំរបាយការណ៍ ការក្លែងបន្លំឯកសារ ត្រូវទទួលទោសព្រហ្មទណ្ឌ ទណ្ឌកម្មរដ្ឋបាល និងទណ្ឌកម្មរដ្ឋប្បវេណី តាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ចំពោះបរធនបាលកិច្ចហិរញ្ញវត្ថុមិនបានចុះបញ្ជីតាមបទប្បញ្ញត្តិជាធរមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងចាត់វិធានការតាមផ្លូវច្បាប់ ដើម្បីដកហូតឱ្យរដ្ឋគ្រប់គ្រងជំនួសនូវសមតុល្យនៃបរធនដែលបាននិងកំពុងកាន់កាប់ដោយបំពាននីតិវិធីចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ។

បទប្បញ្ញត្តិនៃកថាខណ្ឌទី១ និងទី២ ខាងលើ ត្រូវយកមកអនុវត្តផងដែរ ចំពោះអភិបាលបណ្តោះអាសន្ន និងអ្នកជម្រះបញ្ជីរបស់បរធនបាលកិច្ចហិរញ្ញវត្ថុ។

## ជំពូកទី ៩

## អន្តរប្បញ្ញត្តិ

**មាត្រា៣០ .-**

ក្នុងរយៈពេល ០៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទនៃអនុក្រឹត្យនេះ បុគ្គលដែលបាននិងកំពុងគ្រប់គ្រងបរធនត្រូវមកចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា៣១ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូនសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ៤៣៣ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១២/០១០ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០១៣
- បានឃើញអនុក្រឹត្យលេខ ០៤អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៧៦អនក្រ.បក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១២ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកាចំនួន៨ ២៧១ ១០០ ០០០រៀល(ប្រាំបីពាន់ពីររយចិតសិបមួយលានមួយរយពាន់រៀលគត់) ពីជំពូក០៩(ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក៦៥(ឧបត្ថម្ភកធននិងជំនួយសង្គម) ជូនទីស្តីការគណៈរដ្ឋមន្ត្រី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ផ្តល់ជូនអាជ្ញាធរអប្សរា ដើម្បីទូទាត់សងថ្លៃអនុវត្តការងារស្តារនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធតាមបណ្តោយផ្លូវជាតិលេខ ៦ ជំហានទី២ លើកទី១ ជូនកងវិស្វកម្មសម្តេចតេជោខេត្តសៀមរាប ក្នុងឆ្នាំ២០១៣។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ សីហា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៨៥៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យ លេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

**សម្រេច**

**មាត្រា ១:** ប្រគល់ភារកិច្ចជូនលោកស្រី **ប្ងួន មួយឡៀង** ឲ្យបំពេញមុខងារជាប្រធាននាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍ នៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជំនួសលោកស្រី **លឹម លឿង** ដែលត្រូវបានដាក់ឲ្យចូលនិវត្តន៍។

**មាត្រា ២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០១៣*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៨៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

### សម្រេច

**មាត្រា ១.–**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងផ្តល់ជូនសប្បុរសជនចំនួន ០៥រូប ដែលបានខិតខំកៀរគរ និងបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅ**វត្តជម្ពូធិបតីសុវណ្ណព្រីងកោង** ស្ថិតនៅក្នុងឃុំបុស្សរ៍ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ចំណាយអស់ថវិកាសរុបចំនួន ១២.៩២០ដុល្លារ និង៣៣១.៥៨៣.០០០រៀល ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **នន់** | **ប៊ុច** | ព្រះចៅអធិការវត្តជម្ពូធិបតីសុវណ្ណព្រីងកោង |
| ២-លោកស្រី | **គង់** | **ស៊ីណា** | សប្បុរសជននៅខេត្តបាត់ដំបង |
| ៣-លោក | **លិម** | **ប៊ី** | សប្បុរសជននៅខេត្តបន្ទាយមានជ័យ |
| ៤-លោក | **ជុំ** | **នៅ** | សប្បុរសជននៅខេត្តបន្ទាយមានជ័យ |
| ៥-ឧបាសក | **គង់** | **គិម** | សប្បុរសជននៅខេត្តបន្ទាយមានជ័យ |

**មាត្រា ២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ......អនក្រ.បក ៦៥

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

មាត្រា ១.—

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និងផ្ដល់ជូនសប្បុរសជននៅក្នុង និងក្រៅប្រទេសចំនួន ២១ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា នៅ**វត្តនទីចន្ទនារាម** (ហៅវត្តកំពង់ត្រឡាចក្រោម) ស្ថិតនៅក្នុងឃុំកំពង់ត្រឡាច និងនៅ**វត្តចន្ទសុរិយា** (ហៅវត្តក្រឡាញ់) ស្ថិតនៅក្នុងឃុំអូរឫស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលមានរាយព្រះនាម និងនាមដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១-ព្រះតេជគុណ | គង់ | សារ៉េត | ព្រះចៅអធិការវត្តនទីចន្ទនារាម | បច្ច័យចំនួន ១១.២០០ ដុល្លារ |
| ២-ឧបាសិកា | អៀប | គីមជា | សប្បុរសជនខ្មែររស់នៅប្រទេសកាណាដា | ថវិកាចំនួន ២៧.៦៧៥ ដុល្លារ |
| ៣-ឧបាសិកា | អ៊ុំង | ស៊ីវហុង | សប្បុរសជនខ្មែររស់នៅប្រទេសកាណាដា | ថវិកាចំនួន ២៧.៦៧៥ ដុល្លារ |
| ៤-លោកវរសេនីយ៍ឯក | គីម | ចាន់ថន | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ២៧.៤៥៦ ដុល្លារ |
| ៥-លោក | គង់ | អក្ខរា | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១២.០៣០ ដុល្លារ |
| ៦-លោក | ខួន | សុផាន | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.៥៥៨ ដុល្លារ |
| ៧-លោកស្រី | តែ | មួយ | សប្បុរសជននៅខេត្តកំពង់ឆ្នាំង | ថវិកាចំនួន ១១.២៥៦ ដុល្លារ |
| ៨-លោក | គីម | ណារ៉ា | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.២៥៤ ដុល្លារ |

| | | | |
|---|---|---|---|
| ៩-លោកសាស្ត្រាចារ្យ | តាំង ទី | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១១.២៥៤ ដុល្លារ |
| ១០-ឧបាសិកា | ទើក សៀន | សប្បុរសជននៅខេត្តកំពង់ឆ្នាំង | ថវិកាចំនួន ១១.២៥០ ដុល្លារ |
| ១១-ឧបាសិកា | គង់ ឈុន | សប្បុរសជននៅខេត្តកំពង់ឆ្នាំង | ថវិកាចំនួន ១១.២០០ ដុល្លារ |
| ១២-លោក | គុយ ថ្រន | សប្បុរសជននៅខេត្តកំពង់ឆ្នាំង | ថវិកាចំនួន ១១.០៥០ ដុល្លារ |
| ១៣-លោក | ភាច សួរ | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.៥០០ ដុល្លារ |
| ១៤-ឧបាសិកា | ទូច សៀន | សប្បុរសជននៅខេត្តកំពង់ឆ្នាំង | ថវិកាចំនួន ១០.៥០០ ដុល្លារ |
| ១៥-លោកស្រី | អ៊ុង ហ្គិចលាង | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.៤១០ ដុល្លារ |
| ១៦-លោក | ឈី ចាន់ហុង | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.៣៥០ ដុល្លារ |
| ១៧-ឧបាសក | លី ឃន | សប្បុរសជននៅខេត្តកំពង់ឆ្នាំង | ថវិកាចំនួន ១០.២៥០ ដុល្លារ |
| ១៨-លោកឧកញ៉ា | អ៊ុន ឃីម | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.២៥០ ដុល្លារ |
| ១៩-លោកស្រី | ហ៊ុន ម៉ាន់ឌី | សប្បុរសជននៅរាជធានីភ្នំពេញ | ថវិកាចំនួន ១០.១២០ ដុល្លារ |
| ២០-ឧបាសក | គង់ រឹម | គណៈកម្មការវត្តនទីចន្ទនារាម | ថវិកាចំនួន ១០.០៥០ ដុល្លារ |
| ២១-ឧបាសិកា | អ៊ុំ ម៉ន | សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក | ថវិកាចំនួន ១០.០០០ ដុល្លារ |

**មាត្រា ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលខេត្តកំពង់ឆ្នាំង និងសាមីខ្លួន ដែលមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៩៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងផ្តល់ជូនសប្បុរសជននៅក្នុង និងក្រៅប្រទេស ចំនួន ៥៣ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងសមិទ្ធផលនានាក្នុងវិស័យ នៅ**វត្តដូងជ្រុំ វត្តព្រះម្លូរ** និង**វត្តទួលល្មៀប** ស្ថិតនៅក្នុងឃុំបឹងបត់កណ្តាល ឃុំបឹងខ្នារ និងឃុំមេទឹក ស្រុកបាកាន និងនៅ**វត្តបក្សីចាំក្រុង** (ហៅវត្តភ្នំបាក់ត្រា) ស្ថិតនៅក្នុងឃុំព្រងិល ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដែលមានរាយព្រះនាម និងដូចខាងក្រោម :

**ក. មេដាយមាសស្ថាបនាជាតិចំនួន ២៤ គ្រឿង ប្រគេន និងផ្តល់ជូន :**

១-ព្រះតេជគុណកុលវិឡានោ **ជា សុខុម** ព្រះចៅអធិការវត្តទួលល្មៀប បច្ច័យចំនួន ២៤.៨៣៧ ដុល្លារ

២-ព្រះតេជគុណវិនយធរោ **គិន តិរម្យ** ព្រះគ្រូធម្មាចារ្យវត្តនន្ទមុនី បច្ច័យចំនួន ១៤.៣៦០ ដុល្លារ

៣-ព្រះតេជគុណធម្មបញ្ញោ **ឃុយ សុភា** ព្រះចៅអធិការវត្តដូងជ្រុំ បច្ច័យចំនួន ១០.០៣០ ដុល្លារ

